សំរិទ្ធិស័ក

SAMRITHISAK

ដើម្បីអាជីវកម្មឈានមុខគេជានិច្ច

# របាយការណ៍ប្រចាំឆ្នាំ ២០២៣


**ការិយាល័យកណ្តាល**

អគារលេខ ៥០២G,៥០២H មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន  រាជធានីភ្នំពេញ

(៨៥៥) ២៣ ៩៩ ៣៣៣៣
(៨៥៥) ៩៣ ៨៩ ៦៦៦៦

hr@samrithisak.com

facebook.com/samrithisakmfi

@samrithisakig

# មាតិកា


| | |
|---|---|
| ១. ទស្សនវិស័យ និង បេសកកម្ម | ១ |
| ២. សេចក្តីសង្ខេបអំពីគ្រឹះស្ថាន | ១ |
| ៣. ទិដ្ឋភាពទូទៅរបស់សីរីទ្ធិស័ក | ២-៣ |
| ៤. សូចនាករហិរញ្ញវត្ថុសង្ខេប | ៤ |
| ៥. សង្ខេបព័ត៌មានឥណទាន | ៥-៦ |
| ៦. ព័ត៌មានគណៈគ្រប់គ្រងសំខាន់ៗ | ៧-៨ |
| ៧. របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ៩-១៣ |
| ៨. របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម | ១៤ |
| ៨.១. របាយការណ៍សវនករឯករាជ្យ | ១៤-១៧ |
| ៨.២. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ១៨-១៩ |
| ៨.៣. របាយការណ៍ចំណូលលម្អិត | ២០ |
| ៨.៤. របាយការណ៍បម្រែបម្រួលមូលធន | ២២-២៣ |
| ៨.៥. របាយការណ៍លំហូរសាច់ប្រាក់ | ២៤-២៥ |
| ៨.៦. កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ២៦-៧៤ |
| ៩. អាស័យដ្ឋានការិយាល័យកណ្តាលនិងសាខា | ៧៥-៧៦ |



# ទស្សនវិស័យ និង បេសកកម្ម

## ចក្ខុវិស័យ

ជំរើសទីមួយរបស់អតិថិជនគឺមីក្រូហិរញ្ញវត្ថុ និងជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនាំមុខគេក្នុងការ ផ្តល់សេវាមីក្រូហិរញ្ញវត្ថុ។

## បេសកកម្ម

បេសកកម្មរបស់គ្រឹះស្ថាន គឺផ្តល់ឱកាសដល់ ប្រជាពលរដ្ឋកម្ពុជា ក្នុងការកែលំអរជីវភាពរស់នៅ តាមរយៈការទទួលយក សេវាមីក្រូហិរញ្ញវត្ថុ ដែលមានលក្ខណៈសមភាព និង ប្រកួតប្រជែងដោយធានាបាននូវនិរន្តភាព និងអត្ថប្រយោជន៍របស់ អតិថិជន ភាគទុនិក បុគ្គលិក និងសង្គម។

## សេចក្តីសង្ខេបអំពីគ្រឹះស្ថាន

| | |
|---|---|
| ឈ្មោះគ្រឹះស្ថាន | ៖ គ្រឹះស្ថាន សិរីទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត |
| ប្រភេទអាជីវកម្ម | ៖ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត |
| ចុះបញ្ជីលេខ | ៖ ០០០៣២៤៨៩ |
| ការិយាល័យចុះបញ្ជី | ៖ ផ្ទះលេខ ៥០២ហេ្ស ៥០២ ហាស់ មហាវិថី ព្រះមុនីវង្ស សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ |
| សវនករឯករាជ្យ | ៖ KPMG CAMBODIA LTD. |
| បុគ្គលិក | ៖ ១៣៧ |

## ព័ត៌មានរបស់បុគ្គលិក

| | |
|---|---|
| សរុបបុគ្គលិក | : 137 |
| ស្រី | : 48 |
| បុរស | : 89 |

| ការិយាល័យកណ្តាល | | សាខា | | មន្ត្រីឥណទាន | |
|---|---|---|---|---|---|
| ស្រី | : 32 | ស្រី | : 16 | ស្រី | : 01 |
| បុរស | : 50 | ប្រុស | : 39 | បុរស | : 28 |

# ទិដ្ឋភាពទូទៅរបស់សំរឹទ្ធិស័ក




**គ្រឹះស្ថាន សំរឹទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត** ត្រូវបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមរបស់លោក **តាំង ខួន** និងវិនិយោគិនខ្មែរ ចំនួនបួននាក់ទៀតដើម្បីឱ្យគ្រឹះស្ថានមានដើមទុន និងធនធានគ្រប់គ្រាន់សំរាប់បម្រើដល់សេចក្តីត្រូវការ ខាងហិរញ្ញវត្ថុដល់អ្នកមានមុខរបរតូចតាច អ្នកជំនួញសហគ្រិន សិប្បករ អាជីវករ អ្នកផ្តល់សេវាកម្ម កសិករ និងអាជីវកម្មគ្រួសារជាដើម។ នៅក្នុងខែឧសភា ឆ្នាំ២០១០ ទទួលបានអាជ្ញាប័ណ្ណប្រកបអាជីវកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជាដែលមានឈ្មោះជាផ្លូវការថា៖

**សំរឹទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត** និងមានដើមទុនចុះបញ្ជីចំនួន ៥០០.០០០ ដុល្លារអាមេរិក (ប្រាំរយពាន់ដុល្លារ អាមេរិក)។ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០ សំរឹទ្ធិស័កបាន បន្ថែមដើមទុនរហូតដល់ ១.០០០.០០០ ដុល្លារអាមេរិក (មួយលានដុល្លារអាមេរិក)។ ដោយឃើញ នូវសេចក្តីត្រូវការខាងហិរញ្ញវត្ថុ យ៉ាងខ្លាំងរបស់អតិថិជន នៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១៩ សំរឹទ្ធិស័ក ក៏សម្រេចចិត្តបន្ថែមដើមទុនរហូតដល់ ១៥.០០០.០០០ ដុល្លារអាមេរិក (ដប់ប្រាំលានដុល្លារអាមេរិក) ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់ឥណទានជូនអតិថិជនរបស់ខ្លួន។

**សំរឹទ្ធិស័ក** ត្រូវបានបង្កើតឡើងក្នុងគោលបំណងជួយដល់ប្រជាពលរដ្ឋក្រីក្រដែលពុំអាចមានលទ្ធភាពទទួលសេវាហិរញ្ញវត្ថុពីធនាគារក្នុងការស្វែងរកទុនសម្រាប់បង្កើតនិងពង្រីកមុខរបររបស់ពួកគេ។

# ដើមទុនចុះបញ្ជី



# គ្រឹះស្ថាន សំរិទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត

## SAMRITHISAK MICROFINANCE LIMITED




CHAIRMAN BOARD OF DIRECTOR

តាំង_ហុង

# សូចនាករហិរញ្ញវត្ថុសង្ខេប

| សូចនាករហិរញ្ញវត្ថុសង្ខេប | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|
| **សមិទ្ធផលហិរញ្ញវត្ថុ** | | | |
| ចំណូលសរុប | ៤,៩០៨,២៤២ | ៣,៩៦៨,៤៨១ | ៣,៥០៤,៩០២ |
| ចំណាយសរុប | ៣,៨២៩,៨៥៣ | ៣,៤៦០,៣១៧ | ២,៨៩៨,០២០ |
| **ប្រាក់ចំណេញ** | ៥៧៨,៣៨៩ | ៥០៨,១៦៤ | ៦០៦,៨៨២ |
| ទ្រព្យសកម្មសរុប | ២៩,៩៦៨,៨១៩ | ២៦,៨៦៨,៥៩៣ | ២៤,៤៥០,៤៥៨ |
| បំណុលសរុប | ១០,៣៧៧,៦៧៥ | ៦,៧៦៩,២៨៥ | ៣,៨៦៦,១៣៤ |
| មូលធនសរុប | ១៩,៥៩១,១៩៤ | ២០,០៩៩,៣០៨ | ២០,៥៨៤,៣២៤ |
| ដើមទុន | ១៥,000,000 | ១៥,000,000 | ១៥,000,000 |
| ចំណូលធៀបនិងទ្រព្យសកម្ម | ១.៩៣% | ១.៨៩% | ២.៤៨% |
| ចំណូលធៀបនិងមូលធន | ២.៩៥% | ២.៥៣% | ២.៩៥% |
| ឥណទាន និងបុរេប្រទានតាមថ្លៃដើមដករំលស់ | ២៦,០៩៨,៩៨២ | ២៣,៤៣៥,៦២៤ | ២២,១៦៧,៦៩៩ |
| ចំនួនអតិថិជន | ២,១០០ | ១,៧៩៨ | ១,៥៥០ |
| ចំនួនមន្ត្រីឥណទាន | ៥៣ | ៣១ | ២៩ |
| ចំនួនសាខា | ៦ | ៦ | ៦ |
| ឥណទានស្ថិតក្នុងហានិភ័យលើសពី ៣០ថ្ងៃ | ២៣៤,០៣០ | ១៦៤,៣០៨ | ១២៦,៨៩៦ |

## ប្រាក់ចំណេញ





# សង្ខេបព័ត៌មានឥណទាន

## ឥណទានអាជីវកម្ម

ឥណទានអាជីវកម្ម គឺជាប្រភេទឥណទានដែលអតិថិជនយកទៅប្រើប្រាស់ដើម្បីពង្រីកមុខរបរ ឬដំណើរ ការអាជីវកម្មរបស់ខ្លួន និងដាក់ធានាអចលនទ្រព្យដូចជា ដី ដីនិងផ្ទះ ដីស្រែ ដីចំការ ឬតួបតាមបណ្តាផ្សារនានា។

### អត្ថប្រយោជន៍ដែលទទួលបាន

- ទំហំឥណទានរហូតដល់ ៣០០,០០០ ដុល្លារ ឬសមាមាត្រ ១,២០០,០០០,០០០រៀល
- អត្រាការប្រាក់ ១០.២ ភាគរយ ដល់ ១៨ ភាគរយ (ក្នុងមួយឆ្នាំ)
- រយៈពេលចាប់ពី ១៤ខែ ដល់ ១២០ខែ
- តម្រូវអោយមានទ្រព្យធានា
- ឯកសារតម្រូវងាយស្រួល។

### លក្ខណៈអតិថិជន

- អតិថិជនមានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៦៥ឆ្នាំ
- មានទីលំនៅពិតប្រាកដស្ថិតនៅរាជធានីភ្នំពេញ រឺបណ្តាខេត្តមួយចំនួន។

## ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន

ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន គឺជាឥណទានផ្តល់ជូនអតិថិជនជាសាច់ប្រាក់ដើម្បីយកទៅប្រើប្រាស់ តាមតម្រូវការផ្ទាល់ខ្លួនដែលមានដូចជា៖ ទិញអចលនទ្រព្យ គ្រឿងសង្ហារឹម និងសម្ភារៈផ្សេងៗ ជាច្រើនថែម ទៀតសម្រាប់ផ្គត់ផ្គង់ក្នុងជីវភាពរស់នៅ និងកែលម្អសេដ្ឋកិច្ចគ្រួសារឱ្យកាន់តែប្រសើរ។

### អត្ថប្រយោជន៍ដែលទទួលបាន

- ទំហំឥណទានរហូតដល់ ៣០០,០០០ដុល្លារ ឬ ១,២០០,០០០,០០០រៀល
- អត្រាការប្រាក់ ១០.២ ភាគរយ ដល់ ១៨ ភាគរយ (ក្នុងមួយឆ្នាំ)
- អាចបង់រំលស់ ១៤ខែ រហូតដល់ ១២០ ខែ
- អត្រាការប្រាក់សមរម្យ
- តម្រូវអោយមានទ្រព្យដាក់ធានា
- ការអនុម័តឥណទានឆាប់រហ័ស។

### លក្ខណៈអតិថិជន

- អតិថិជនមានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៦៥ឆ្នាំ
- មានទីលំនៅពិតប្រាកដស្ថិតនៅរាជធានីភ្នំពេញ រឺតាមបណ្តាខេត្តមួយចំនួន។

# ផលិតផលឥណទាន




សំរិទ្ធិស័ក
SAMRITHISAK
ឥណទាន
អាជីវកម្ម
BUSINESS LOAN
ផ្តល់ជូនកម្ចីរហូតដល់៖
$300,000
ទំនាក់ទំនង៖
097 761 3333 | 093 222 909


សំរិទ្ធិស័ក
SAMRITHISAK
ឥណទាន
ប្រើប្រាស់ផ្ទាល់ខ្លួន
$50,000
ផ្តល់កម្ចី
ជូនរហូតដល់

# ព័ត៌មានគណៈគ្រប់គ្រងសំខាន់ៗ



### លោក តាំង ហុង
**ប្រធានក្រុមប្រឹក្សាភិបាល**

**លោក តាំង ហុង** ជាប្រធានក្រុមប្រឹក្សាភិបាលរបស់ **សិរីទ្ធិស័ក** នៅឆ្នាំ ២០១៧។ គាត់កើតនៅឆ្នាំ ១៩៧០ មានដើមកំណើតជាជនជាតិខ្មែរ។ ចាប់តាំងពីឆ្នាំ ១៩៩៤ រហូតដល់សព្វថ្ងៃ លោកជាវិនិយោគិន ម្នាក់ដែលទទួលបានជោគជ័យ។ លោកជាភាគទុនិក និង ជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ស្ពតធីងឡាយគ្រុប ខូអិលធីឌី និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុន មេគង្គគ្លីននីរគ្រុប ខូអិលធីឌី។ គាត់បាន បញ្ចប់បរិញ្ញាបត្រហិរញ្ញវត្ថុនិងធនាគារ។



### លោក តាំង ខួន
**អគ្គនាយក**

**លោក តាំង ខួន** ជាអនុប្រធានក្រុមប្រឹក្សាភិបាលរបស់ **សិរីទ្ធិស័ក** នៅក្នុងឆ្នាំ ២០១៧។ គាត់បានកើតនៅឆ្នាំ ១៩៦៩ មានដើមកំណើតជាជនជាតិខ្មែរ។ ចាប់តាំងពីឆ្នាំ ១៩៩០ រហូតដល់សព្វថ្ងៃ លោកជាវិនិយោគិនម្នាក់ដែលទទួលបានជោគជ័យ។ លោកជាភាគទុនិក និងសមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ស្ពតធីងឡាយគ្រុបខូអិលធីឌី និង ក្រុមហ៊ុនមេគង្គគ្លីននីរគ្រុបខូអិលធីឌី។



### លោក ជាង ស៊ីវណ្ណលាង
**សមាជិកក្រុមប្រឹក្សាភិបាល**

**លោក ជាង ស៊ីវណ្ណលាង** ជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ **សិរីទ្ធិស័ក** ក្នុងឆ្នាំ ២០១០។ គាត់បានកើតនៅក្នុងឆ្នាំ ១៩៥៥ មានដើមកំណើតជាជនជាតិខ្មែរ។ ចាប់តាំងពីឆ្នាំ ១៩៩០ រហូតដល់សព្វថ្ងៃ លោកជា វិនិយោគិនម្នាក់ដែលទទួលបានជោគជ័យ។ លោកជាភាគទុនិក និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនមេគង្គគ្លីននីរគ្រុប ខូអិលធីឌី លោកបានបញ្ចប់បរិញ្ញាបត្រ គ្រប់គ្រងពាណិជ្ជកម្ម។

# គណៈកម្មាធិការប្រតិបត្តិ



### លោក តាំង ខួន
**អនុប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក**

**លោក តាំង ខួន** ជាអនុប្រធានក្រុមប្រឹក្សាភិបាលរបស់ សិរីទ្ធិស័ក ក្នុងឆ្នាំ ២០១៧។ គាត់បានកើតនៅឆ្នាំ ១៩៦៩ មានដើមកំណើតជាជនជាតិខ្មែរ។ ចាប់តាំងពីឆ្នាំ ១៩៩០ រហូតដល់សព្វថ្ងៃ លោកជាវិនិយោគិនម្នាក់ដែលទទួលបានជោគជ័យ។ លោកជាភាគទុនិកនិងសមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ស្ពតធីងឡាយគ្រុប ខូអិលធីឌី និងក្រុមហ៊ុនមេគង្គគ្លីននីរគ្រុប ខូអិលធីឌី។ លោក តាំង ងួន បានបញ្ចប់បរិញ្ញាបត្រគ្រប់គ្រងទូទៅ។



## លោក ប៊ុន ធីដាវ

### អនុប្រធាននាយកប្រតិបត្តិ

**លោក ប៊ុន ធីដាវ** កើតនៅឆ្នាំ ១៩៨០ នៅខេត្តកំពង់ចាម។ លោកបានចូលបម្រើការងារជាមួយ **សិរីទ្ធិស័ក** ក្នុងឆ្នាំ ២០១០ មានតួនាទីជាអនុប្រធាននាយកប្រតិបត្តិ។ គាត់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកធនាគារនិងហិរញ្ញវត្ថុ និង បានបញ្ចប់ថ្នាក់អនុបណ្ឌិតគ្រប់គ្រងទូទៅ នៅសាកវិទ្យាល័យបៀលប្រាយ។ លោកបាន ចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដែលទាក់ទងនឹងការគ្រប់គ្រង។ មុនគាត់ចូលបំរើការងារក្នុង **សិរីទ្ធិស័ក** គាត់ធ្លាប់បានបំរើការងារជាប្រធានទីផ្សារនៅក្រុមហ៊ុនថៃសាវ៉ាកាលពីឆ្នាំ ២០០៤ នៅក្នុងប្រទេសកម្ពុជា។

# ភាគទុនិក





# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមធ្វើការបង្ហាញជូននូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើ សវនកម្មរួចរបស់ ស៊ីរីទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត ហៅកាត់ថា (“ក្រុមហ៊ុន”) សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន រួមមានការធ្វើប្រតិបត្តិការក្នុងការផ្តល់សេវាមីក្រូហិរញ្ញវត្ថុ និងការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុដែលពាក់ព័ន្ធផ្សេងៗ ក្នុងវិសាលភាពនៃអាជ្ញាបណ្ណមីក្រូហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ត្រូវបានបង្ហាញនៅ ទំព័រទី12។

## ដើមទុន

ពុំមានការប្រែប្រួលរចនាសម្ព័ន្ធភាគហ៊ុន ក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ។ សូមមើលកំណត់សម្គាល់ 17 សម្រាប់ព័ត៌មានលម្អិត។

## ភាគលាភ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានការប្រកាស ឬបែងចែកភាគលាភឡើយ ហើយក្រុមប្រឹក្សាភិបាលក៏ពុំមាន អនុសាសន៍ឱ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 នោះឡើយ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះឡើយ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានាដើម្បីឈានដល់ការអះអាងថា នីតិវិធីពាក់ព័ន្ធជាមួយនឹងការលុបចោលឥណទានអាក្រក់ និងការធ្វើ សំវិធានធនលើឥណទានជាប់សង្ស័យ ត្រូវបានយកមកអនុវត្ត ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ឥណទានអាក្រក់ដែលបានដឹងថាមិនអាចទារបានត្រូវបានលុបចោល ហើយសំវិធានធនត្រូវបាន ប៉ាន់ស្មានសមស្របសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយដែលអាចបណ្តាលឱ្យ ចំនួនទឹកប្រាក់នៃឥណទានអាក្រក់ដែលបានលុបចោល ឬចំនួនទឹកប្រាក់សំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

## ទ្រព្យសកម្ម

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ សមស្របនានា ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងអស់ក្រៅពីឥណទាន ដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាក្នុងតម្លៃរបស់វាដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យ ត្រូវបានបន្ថយនៅស្មើនឹងតម្លៃដែលគិតថានឹងអាចទទួលស្គាល់បានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលអាចបណ្តាលឱ្យការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង ហើយនឹងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និង បំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ គឺពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុនឡើយ។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងទៀតរបស់ក្រុមហ៊ុនដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល 12ខែ បន្ទាប់ពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលនឹងធ្វើឱ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានព្រឹត្តិការណ៍ជាសារវន្តផ្សេងទៀតកើតឡើង បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ដែលតម្រូវឱ្យមានការលាតត្រដាង ឬកែតម្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលបានបម្រើការនៅក្នុងអំឡុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះ រួមមាន៖

| | |
|---|---|
| លោក តាំង ហុង | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក តាំង ងួន | អភិបាល |
| លោក គុជ ស៊ីថា | អភិបាល |
| លោក ជាង ស៊ីវណ្ណលាង | អភិបាល |
| លោក យឿន ប៊ុនយឹម | អភិបាល |

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និង មិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទហិរញ្ញវត្ថុដល់ថ្ងៃចេញ របាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឱ្យប៉ះពាល់ជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុង កាលបរិច្ឆេទហិរញ្ញវត្ថុ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ភាគកម្មរបស់អភិបាល

អភិបាលដែលកាន់មុខតំណែងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុ និង ភាគកម្មរបស់ពួកគាត់នៅក្នុងភាគហ៊ុនរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | %នៃ កម្មសិទ្ធិ | ចំនួន ភាគហ៊ុន | ទឹកប្រាក់ ដុល្លារអាមេរិក | %នៃ កម្មសិទ្ធិ | ចំនួន ភាគហ៊ុន | ទឹកប្រាក់ ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| លោក តាំង ងួន | 58.00% | 87,000 | 8,700,000 | 58.00% | 87,000 | 8,700,000 |
| លោក តាំង ហុង | 37.67% | 56,500 | 5,650,000 | 37.67% | 56,500 | 5,650,000 |
| លោក ជាង ស៊ីវណ្ណលាង | 3.67% | 5,500 | 550,000 | 3.67% | 5,500 | 550,000 |

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជា ភាគីម្ខាងដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះបានផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ឱ្យទទួលបាន នូវអត្ថប្រយោជន៍តាមមធ្យោបាយនៃការទិញភាគហ៊ុននោះឡើយ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមុន ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវ អត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះ កិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយសាជីវកម្មពាក់ព័ន្ធណាមួយ ជាមួយនឹងក្រុមហ៊ុនណាមួយដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិកនៃក្រុមហ៊ុននោះ ឬដែលអភិបាលនោះមានភាគកម្មផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ លើកលែងតែអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីចង្អុលបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

- អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព

- អនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ គឺត្រូវតែបង្ហាញ ពន្យល់ និងកំណត់បរិមាណឱ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ

- ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបាន គ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព

- វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យលើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

- ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងអស់ដែល ប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក្រុមប្រឹក្សាភិបាលបានអនុវត្តនូវរាល់តម្រូវការដូចមានរាយការណ៍ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

# ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ខ្ញុំបាទ តំណាងឱ្យក្រុមប្រឹក្សាភិបាល សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុរួមទាំងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ ដូចដែលបានបង្ហាញនៅទំព័រទី10 ដល់ទី70 ថាបានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបាន បញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម។

*ចុះហត្ថលេខាដោយយោងលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល៖*

លោក តាំង ហុង

*ប្រធានក្រុមប្រឹក្សាភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី21 ខែមេសា ឆ្នាំ2023

# របាយការណ៍របស់សវនករឯករាជ្យ ជូនចំពោះភាគទុនិករបស់ សំរិទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត

## មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ សំរិទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត ហៅកាត់ថា (“ក្រុមហ៊ុន”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 របាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀត ដូចបានបង្ហាញនៅទំព័រទី10 ដល់ទី70 (ដែលហៅកាត់ថា “របាយការណ៍ហិរញ្ញវត្ថុ”)។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដាទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពី ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានភាពឯករាជ្យពីក្រុមហ៊ុន ដោយស្របទៅតាមលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌វិជ្ជាជីវៈនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌វិជ្ជាជីវៈផ្សេងៗទៀតស្របតាមលក្ខខណ្ឌតម្រូវទាំងនេះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និង សមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## ការទាញចំណាប់អារម្មណ៍លើបញ្ហា - ព័ត៌មានប្រៀបធៀប

យើងខ្ញុំសូមទាញចំណាប់អារម្មណ៍លើកំណត់សម្គាល់ 32 នៃរបាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញថាព័ត៌មានប្រៀបធៀបនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងថ្ងៃទី1 ខែមករា ឆ្នាំ2021 និងរបាយការណ៍លទ្ធផលលម្អិត និងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ត្រូវបានរាយការណ៍ឡើងវិញ។ មតិរបស់យើងខ្ញុំមិនត្រូវបានកែប្រែដោយសារបញ្ហានេះទេ។

## បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ មិនបានរាប់បញ្ចូលនិយ័តកម្មដែលបានពណ៌នានៅក្នុងកំណត់សម្គាល់ 32 នៃរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេង ដែលបានបញ្ចេញមតិនៅថ្ងៃទី21 ខែមីនា ឆ្នាំ2022 ថារបាយការណ៍ហិរញ្ញវត្ថុទាំងនោះមានភាពត្រឹមត្រូវ។

ជាផ្នែកមួយនៃការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 យើងខ្ញុំ បានធ្វើសវនកម្មលើនិយ័តកម្មដែលបានពណ៌នានៅក្នុងកំណត់សម្គាល់ 32 ដែលត្រូវបានធ្វើឡើងដើម្បីរាយការណ៍ឡើងវិញនូវព័ត៌មានប្រៀបធៀបដែលបានបង្ហាញនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី1 ខែមករា ឆ្នាំ2021។ យើងខ្ញុំ មិនបានធ្វើសវនកម្ម ត្រួតពិនិត្យ ឬអនុវត្តនីតិវិធីណាមួយចំពោះរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ឬថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 (មិនមានបង្ហាញនៅទីនេះ) ឬចំពោះរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី1 ខែមករា ឆ្នាំ2021 នោះឡើយ ក្រៅតែពីនិយ័តកម្មដូចដែលបានពណ៌នានៅក្នុងកំណត់សម្គាល់ 32 នៃរបាយការណ៍ហិរញ្ញវត្ថុ។ ហេតុដូច្នេះ យើងខ្ញុំ មិនបញ្ចេញមតិសវនកម្ម ឬទម្រង់ជាការធានាអះអាងណាមួយ លើរបាយការណ៍ហិរញ្ញវត្ថុទាំងនោះជារួមនោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ជាមតិរបស់យើងខ្ញុំ និយ័តកម្មដែលបានពណ៌នានៅក្នុងកំណត់សម្គាល់ 32 គឺមានលក្ខណៈសមស្រប និងត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមាន គឺរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ដែលបានបង្ហាញនៅទំព័រទី1 ដល់ទី5។ មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗនេះឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មានផ្សេងៗនេះទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬ ការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឱ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗ នេះទេ។

## ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រង និង អ្នកទទួលខុសត្រូវលើអភិបាលកិច្ចលើរបាយការណ៍ហិរញ្ញវត្ថុ

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និង ការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឱ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធ នូវបញ្ហាទាំងឡាយ ដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀត ក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្ម របាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺទទួលបាននូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូល មិនមានការ បង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករ ដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមួយដែលមានកម្រិតខ្ពស់ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុស អាចកើតឡើងដោយសារការក្លែងបន្លំ ឬ កំហុសឆ្គងហើយត្រូវបានចាត់ទុកថាមានលក្ខណៈសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងដោយឡែក ឬក៏រួមបញ្ចូលគ្នាអាចត្រូវបានរំពឹងទុកយ៉ាងសមហេតុផលថា នឹងជះឥទ្ធិពលដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយមក្នុងអំឡុងពេលធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការតាក់តែង និងអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យនៃការរកមិនឃើញនូវការបង្ហាញខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសដែលបណ្តាលមកពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចទាក់ទិននឹងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីតាក់តែងនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។
- ធ្វើការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានអនុវត្ត និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធនានា ដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើ ភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតមានឡើងពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចបង្កឱ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុន ដើម្បីបន្តនិរន្តរភាពអាជីវកម្មដែរឬទេ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវទាញចំណាប់អារម្មណ៍ នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឱ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពនៃអាជីវកម្ម។
- ធ្វើការវាយតម្លៃលើការបង្ហាញ ទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដោយរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំ ផ្តល់ព័ត៌មាន ក្នុងចំណោមបញ្ហាផ្សេងៗ ជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្ត ដោយរួមបញ្ចូលទាំងចំណុចខ្វះខាតជាសារវន្តក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា**




**ហ្វេក ផាន**

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី21 ខែមេសា ឆ្នាំ2023

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទ៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ដុល្លារអាមេរិក | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ពាន់រៀល (កំណត់សម្គាល់ 5) | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ដុល្លារអាមេរិក | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ពាន់រៀល (កំណត់សម្គាល់ 5) | ថ្ងៃទី1 ខែមករា ឆ្នាំ2021 ដុល្លារអាមេរិក | ថ្ងៃទី1 ខែមករា ឆ្នាំ2021 ពាន់រៀល (កំណត់សម្គាល់ 5) |
|---|---|---|---|---|---|---|---|
| | | | | *(ត្រូវបានរាយការណ៍ឡើងវិញ)* | | *(ត្រូវបានរាយការណ៍ឡើងវិញ)* | |
| **ទ្រព្យសកម្ម** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | 6 | 16,889 | 69,532 | 48,450 | 197,385 | 10,029 | 40,567 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 7 | 763,086 | 3,141,625 | 760,351 | 3,097,670 | 759,996 | 3,074,184 |
| សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា | 8 | 821,133 | 3,380,605 | 2,431,177 | 9,904,615 | 2,561,792 | 10,362,448 |
| ឥណទានផ្តល់ដល់អតិថិជន | 9 | 21,972,285 | 90,459,897 | 23,260,307 | 94,762,491 | 26,098,982 | 105,570,382 |
| ទ្រព្យសកម្មផ្សេងៗ | 10 | 115,650 | 476,132 | 22,900 | 93,294 | 22,208 | 89,831 |
| ទ្រព្យ និងបរិក្ខារ | 11 | 702,422 | 2,891,871 | 351,723 | 1,432,920 | 464,510 | 1,878,943 |
| ទ្រព្យសកម្មអរូបី | 12 | 6,922 | 28,498 | 8,040 | 32,755 | 9,159 | 37,048 |
| ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ | 16ឃ | 52,071 | 214,376 | 59,673 | 243,108 | 47,228 | 191,037 |
| **ទ្រព្យសកម្មសរុប** | | 24,450,458 | 100,662,536 | 26,942,621 | 109,764,238 | 29,973,904 | 121,244,440 |

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ត)
# នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ដុល្លារអាមេរិក | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ពាន់រៀល (កំណត់សម្គាល់ 5) | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ដុល្លារអាមេរិក (ត្រូវបានរាយការណ៍ឡើងវិញ) | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ពាន់រៀល (កំណត់សម្គាល់ 5) (ត្រូវបានរាយការណ៍ឡើងវិញ) | ថ្ងៃទី1 ខែមករា ឆ្នាំ2021 ដុល្លារអាមេរិក (ត្រូវបានរាយការណ៍ឡើងវិញ) | ថ្ងៃទី1 ខែមករា ឆ្នាំ2021 ពាន់រៀល (កំណត់សម្គាល់ 5) (ត្រូវបានរាយការណ៍ឡើងវិញ) |
|---|---|---|---|---|---|---|---|
| **បំណុល និងមូលធន** | | | | | | | |
| **បំណុល** | | | | | | | |
| ប្រាក់កម្ចី | 13 | 3,638,996 | 14,981,747 | 6,461,919 | 26,325,858 | 9,799,829 | 39,640,306 |
| កាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | 14 | 6,004 | 24,718 | 12,175 | 49,601 | 15,525 | 62,799 |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | 16គ | 122,552 | 504,547 | 55,070 | 224,355 | 149,179 | 603,429 |
| បំណុលផ្សេងៗ | 15 | 98,582 | 405,862 | 473,842 | 1,930,432 | 418,227 | 1,691,728 |
| **បំណុលសរុប** | | 3,866,134 | 15,916,874 | 7,003,006 | 28,530,246 | 10,382,760 | 41,998,262 |
| **មូលធន** | | | | | | | |
| ដើមទុន | 17 | 15,000,000 | 60,675,000 | 15,000,000 | 60,675,000 | 15,000,000 | 60,675,000 |
| វិភាគទានដើមទុន | 18 | 1,411,601 | 5,711,515 | 1,373,774 | 5,556,916 | 1,373,774 | 5,556,916 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 19 | 168,133 | 684,791 | 206,947 | 844,588 | 236,978 | 958,576 |
| ប្រាក់ចំណេញរក្សាទុក | | 4,004,590 | 16,329,612 | 3,358,894 | 13,689,488 | 2,980,392 | 12,055,686 |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | - | 1,344,744 | - | 468,000 | - | - |
| **មូលធនសរុប** | | 20,584,324 | 84,745,662 | 19,939,615 | 81,233,992 | 19,591,144 | 79,246,178 |
| **បំណុល និងមូលធនសរុប** | | 24,450,458 | 100,662,536 | 26,942,621 | 109,764,238 | 29,973,904 | 121,244,440 |

# របាយការណ៍លទ្ធផលលម្អិត
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

| | | 2022 | | 2021 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| | | | | *(ត្រូវបានរាយការណ៍ឡើងវិញ)* | |
| ចំណូលការប្រាក់ | 20 | 3,366,607 | 13,759,323 | 4,061,565 | 16,522,446 |
| ចំណាយការប្រាក់ | 21 | (409,856) | (1,675,081) | (737,286) | (2,999,279) |
| **ចំណូលពីការប្រាក់សុទ្ធ** | | 2,956,751 | 12,084,242 | 3,324,279 | 13,523,167 |
| ចំណូល/(ចំណាយ)លើកម្រៃជើងសា និងប្រាក់កម្រៃសុទ្ធ | 22 | 1,220 | 4,986 | (1,671) | (6,798) |
| ចំណូលផ្សេងៗ | 23 | 130,934 | 535,127 | 21,065 | 85,693 |
| **ប្រាក់ចំណូលប្រតិបត្តិការសុទ្ធ** | | 3,088,905 | 12,624,355 | 3,343,673 | 13,602,062 |
| ការខាតបង់លើឱនភាពនៃតម្លៃ ឧបករណ៍ហិរញ្ញវត្ថុសុទ្ធ | 9 | (7,666) | (31,331) | (127,831) | (520,017) |
| ចំណាយលើបុគ្គលិក | 24 | (1,628,209) | (6,654,490) | (2,093,277) | (8,515,451) |
| រំលស់ | 25 | (154,029) | (629,517) | (138,183) | (562,128) |
| ចំណាយលើប្រតិបត្តិការផ្សេងៗ | 26 | (528,994) | (2,161,998) | (555,413) | (2,259,420) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | 770,007 | 3,147,019 | 428,969 | 1,745,046 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 16ខ | (163,125) | (666,692) | (80,498) | (327,466) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | 606,882 | 2,480,327 | 348,471 | 1,417,580 |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | | |
| *ធាតុដែលមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញក្នុងចំណេញ ឬខាត* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 876,744 | - | 565,680 |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | 606,882 | 3,357,071 | 348,471 | 1,983,260 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

សំរិទ្ធិស័ក

SAMRITHISAK

ដើម្បីអាជីវកម្មឈានមុខគេជានិច្ច



# ឥណទាន អាជីវកម្ម

**BUSINESS LOAN**

**ទំហំកម្ចីរហូតដល់៖**

# $300,000

**ទំនាក់ទំនង៖**

**097 761 3333 | 093 222 909**

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | ដើមទុន | | វិភាគទានដើមទុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ថ្ងៃទី 1 ខែមករា ឆ្នាំ 2022 (ត្រូវបានរាយការណ៍ឡើងវិញ) | 15,000,000 | 60,675,000 | 1,373,774 | 5,556,916 | 206,947 | 844,588 | 3,358,894 | 13,689,488 | - | 468,000 | 19,939,615 | 81,233,992 |
| **ប្រតិបត្តិការបានទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន** | | | | | | | | | | | | |
| វិភាគទានដើមទុន | - | - | 37,827 | 154,599 | - | - | - | - | - | - | 37,827 | 154,599 |
| ផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិ ទៅប្រាក់ចំណេញរក្សាទុក (កំណត់សម្គាល់ 19) | - | - | - | - | (38,814) | (159,797) | 38,814 | 159,797 | - | - | - | - |
| | - | - | 37,827 | 154,599 | (38,814) | (159,797) | 38,814 | 159,797 | - | - | 37,827 | 154,599 |
| ***លទ្ធផលលម្អិតសរុប៖*** | | | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | - | - | 606,882 | 2,480,327 | - | - | 606,882 | 2,480,327 |
| លទ្ធផលលម្អិតផ្សេងៗ- លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | 876,744 | - | 876,744 |
| **លទ្ធផលលម្អិតសរុប** | - | - | - | - | - | - | 606,882 | 2,480,327 | - | 876,744 | 606,882 | 3,357,071 |
| ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2022 | 15,000,000 | 60,675,000 | 1,411,601 | 5,711,515 | 168,133 | 684,791 | 4,004,590 | 16,329,612 | - | 1,344,744 | 20,584,324 | 84,745,662 |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្ងៃទី 1 ខែមករា ឆ្នាំ2021 (ត្រូវបានរាយការណ៍ឡើងវិញ) | | | | | | | | | | | | |
| **ប្រតិបត្តិការបានទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន** | | | | | | | | | | | | |
| ផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិ ទៅប្រាក់ចំណេញរក្សាទុក (កំណត់សម្គាល់ 19) | - | - | - | - | (30,031) | (122,346) | 30,031 | 122,346 | - | - | - | - |
| ***លទ្ធផលលម្អិតសរុប៖*** | | | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | - | - | 348,471 | 1,422,135 | - | - | 348,471 | 1,422,135 |
| លទ្ធផលលម្អិតផ្សេងៗ- លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | 565,680 | - | 565,680 |
| **លទ្ធផលលម្អិតសរុប** | - | - | - | - | - | - | 348,471 | 1,422,135 | - | 565,680 | 348,471 | 1,987,815 |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | 15,000,000 | 60,675,000 | 1,373,774 | 5,556,916 | 206,947 | 844,588 | 3,358,894 | 13,689,488 | - | 468,000 | 19,939,615 | 81,233,992 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍លំហូរទឹកប្រាក់
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | 2022 ដុល្លារអាមេរិក | 2022 ពាន់រៀល (កំណត់សម្គាល់ 5) | 2021 ដុល្លារអាមេរិក | 2021 ពាន់រៀល (កំណត់សម្គាល់ 5) |
|---|---|---|---|---|---|
| | | | | *(ត្រូវបានរាយការណ៍ឡើងវិញ)* | |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | | 606,882 | 2,480,327 | 348,471 | 1,417,580 |
| *និយ័តភាពលើ៖* | | | | | |
| ចំណូលការប្រាក់ | 20 | (3,366,607) | (13,759,323) | (4,061,565) | (16,522,446) |
| ចំណាយការប្រាក់ | 21 | 409,856 | 1,675,081 | 737,286 | 2,999,279 |
| ការខាតបង់លើឱនភាពនៃតម្លៃ ឧបករណ៍ហិរញ្ញវត្ថុសុទ្ធ | 9 | 7,666 | 31,331 | 127,831 | 520,017 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 16ខ | 163,125 | 666,692 | 80,498 | 327,466 |
| រំលស់ | 25 | 154,029 | 629,517 | 138,183 | 562,128 |
| កាតព្វកិច្ចអត្ថប្រយោជន៍ និយោជិត | 14 | 65,763 | 268,773 | 70,301 | 285,984 |
| ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ | | (20,384) | (83,309) | - | - |
| (ចំណេញ)/ខាតពីការប្តូររូបិយប័ណ្ណ បរទេសមិនបានទទួលស្គាល់ | | (1,182) | (4,831) | 2,447 | 9,954 |
| | | (1,980,852) | (8,095,742) | (2,556,548) | (10,400,038) |
| *បម្រែបម្រួលនូវ៖* | | | | | |
| ឥណទានផ្តល់ដល់អតិថិជន | | 1,341,121 | 5,481,162 | 2,807,721 | 11,421,809 |
| ទ្រព្យសកម្មផ្សេងៗ | | (24,537) | (100,283) | (692) | (2,815) |
| បំណុលផ្សេងៗ | | (340,264) | (1,390,659) | 12,695 | 51,644 |
| សាច់ប្រាក់(ប្រើប្រាស់ក្នុង)/ ទទួលបានពីប្រតិបត្តិការ | | (1,004,532) | (4,105,522) | 263,176 | 1,070,600 |
| ការប្រាក់បានទទួល | | 3,313,436 | 13,542,013 | 3,973,624 | 16,164,702 |
| ការប្រាក់បានបង់ | | (376,834) | (1,540,121) | (651,194) | (2,649,057) |
| ពន្ធលើប្រាក់ចំណេញបានបង់ | 16គ | (156,254) | (638,610) | (187,052) | (760,928) |
| កាតព្វកិច្ចអត្ថប្រយោជន៍ និយោជិតបានបង់ | 14 | (71,934) | (293,994) | (73,651) | (299,612) |
| **សាច់ប្រាក់សុទ្ធទទួលបានពី សកម្មភាពប្រតិបត្តិការ** | | 1,703,882 | 6,963,766 | 3,324,903 | 13,525,705 |

# របាយការណ៍លំហូរទឹកប្រាក់ (ត)

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | | 2022 | | 2021 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5 (ត្រូវបានរាយការណ៍ឡើងវិញ) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | | (524,797) | (2,144,845) | (24,277) | (98,759) |
| សាច់ប្រាក់បានពីការលក់ទ្រព្យ និងបរិក្ខារ | | 41,571 | 169,900 | - | - |
| ការដកប្រាក់បញ្ញើតាមកាលកំណត់ | | 700,000 | 2,860,900 | 1,100,000 | 4,474,800 |
| **សាច់ប្រាក់សុទ្ធទទួលបានពី សកម្មភាពវិនិយោគ** | | 216,774 | 885,955 | 1,075,723 | 4,376,041 |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | 13 | 1,840,000 | 7,520,080 | 1,667,800 | 6,784,610 |
| ការទូទាត់សងប្រាក់កម្ចី | 13 | (4,656,936) | (19,032,897) | (5,094,249) | (20,723,405) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពហិរញ្ញប្បទាន** | | (2,816,936) | (11,512,817) | (3,426,449) | (13,938,795) |
| **ការ(ថយចុះ)/កើនឡើងសុទ្ធនៃ សាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | (896,280) | (3,663,096) | 974,177 | 3,962,951 |
| **សាច់ប្រាក់ និងសាច់ប្រាក់ សមមូលនាថ្ងៃទី1 ខែមករា** | | 1,734,379 | 7,065,859 | 760,202 | 3,075,017 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 47,691 | - | 27,891 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី31 ខែធ្នូ** | 28 | 838,099 | 3,450,454 | 1,734,379 | 7,065,859 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

កំណត់សម្គាល់ទាំងនេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ហើយគួរតែត្រូវបានអានជាមួយគ្នានឹងរបាយការណ៍ ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ។

## ១. អំពីក្រុមហ៊ុន

សេរីទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត ហៅកាត់ថា (“ក្រុមហ៊ុន”) គឺជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមការចុះបញ្ជីលេខ 00032489 ចុះថ្ងៃទី4 ខែមីនា ឆ្នាំ2010 ចេញដោយក្រសួងពាណិជ្ជកម្ម។ នៅថ្ងៃទី25 ខែឧសភា ឆ្នាំ2010 ក្រុមហ៊ុនបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាដើម្បីប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន រួមមានការធ្វើប្រតិបត្តិការក្នុងការផ្តល់សេវាមីក្រូហិរញ្ញវត្ថុ និងការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុដែលពាក់ព័ន្ធផ្សេងៗ ក្នុងវិសាលភាពនៃអាជ្ញាបណ្ណមីក្រូហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅ អគារលេខ 502G-502H មហាវិថីព្រះមុនីវង្ស សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ក្រុមហ៊ុនមានសាខាចំនួន 7 សាខា (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ 7 សាខា)។

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ក្រុមហ៊ុនមាននិយោជិតចំនួន137 នាក់ (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ 132 នាក់)។

## ២. មូលដ្ឋាននៃការរៀបចំ

### ក. របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម។

ព័ត៌មានលម្អិតទាក់ទងនឹងគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ 31។

### ខ. មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋានថ្លៃដើមដំបូង។

## ៣. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

ក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនជាពីររូបិយប័ណ្ណគឺ ប្រាក់រៀលខ្មែរ និងប្រាក់ដុល្លារអាមេរិក។ អ្នកគ្រប់គ្រងបានកំណត់ថា ប្រាក់ដុល្លារអាមេរិក គឺជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ តួលេខទាំងអស់ត្រូវបានកាត់ខ្ទង់ចំនួនមួយដុល្លារអាមេរិកដែលជិតបំផុត ឬមួយពាន់រៀល លុះត្រាតែមានការបង្ហាញផ្សេងពីនោះ។

## ៤. ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ អ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនេះ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែលើការប៉ាន់ស្មានគណនេយ្យត្រូវបានទទួលស្គាល់តាមវិធីសាស្រ្តទស្សនវិស័យ។

ព័ត៌មានអំពីភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន ដែលមានហានិភ័យជាសារវន្តដែលអាចធ្វើឱ្យមាននិយ័តភាពនៅក្នុងការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ដែលទាក់ទងនឹងឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញដូចខាងក្រោម៖

- កំណត់សម្គាល់ 31ខ (vii) ការកំណត់ និងការវាស់វែងលើឱនភាពនៃតម្លៃ។

## ៥. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិក ទៅជាប្រាក់រៀល បានបំពេញតាមលក្ខខណ្ឌតម្រូវនៃការបង្ហាញព័ត៌មានដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ហើយការប្តូររូបិយប័ណ្ណនេះធ្វើឡើងដោយអនុលោម ទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ផ្នែកទី30 ការប្តូររូបិយប័ណ្ណបរទេស ។

ទ្រព្យសកម្ម និងបំណុល ត្រូវបានប្តូរតាមអត្រានាកាលបរិច្ឆេទរាយការណ៍ ហើយដើមទុន និងគណនីមូលធនផ្សេងៗ ត្រូវបានប្តូរតាមអត្រាប្រវត្តិសាស្រ្ត។ របាយការណ៍លទ្ធផលលម្អិត និងរបាយការណ៍លំហូរទឹកប្រាក់ត្រូវបានប្តូររូបិយប័ណ្ណទៅជាប្រាក់រៀលដោយប្រើប្រាស់អត្រាមធ្យមនៅក្នុងការិយបរិច្ឆេទ ដែលអត្រានេះត្រូវបានចាត់ទុកថាមានលក្ខណៈសមស្រប ពីព្រោះអត្រានេះមិនមានការប្រែប្រួលជាសារវន្តនៅក្នុងការិយបរិច្ឆេទ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា "លម្អៀងពីការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ក្រុមហ៊ុនប្រើប្រាស់អត្រាប្តូររូបិយប័ណ្ណដូចខាងក្រោម៖

| | | | អត្រានាកាលបរិច្ឆេទ | |
|---|---|---|---|---|
| ការិយបរិច្ឆេទដែលបានបញ្ចប់ | | | រាយការណ៍ | អត្រាមធ្យម |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | 1 ដុល្លារអាមេរិក | = | 4,117 រៀល | 4,087 រៀល |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | 1 ដុល្លារអាមេរិក | = | 4,074 រៀល | 4,068 រៀល |

តួលេខជាប្រាក់រៀលនេះ គឺសម្រាប់ជាការបង្ហាញតែប៉ុណ្ណោះ ហើយមិនត្រូវបានយកមកបកស្រាយថាតួលេខប្រាក់ដុល្លារអាមេរិកនេះ ត្រូវបានប្តូរទៅជាប្រាក់រៀល ឬគួរត្រូវបានប្តូរជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

## ៦. សាច់ប្រាក់ក្នុងដៃ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
ក្រុមហ៊ុនវាស់វែងតម្លៃ សមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើសម្រង់តម្លៃនៅក្នុងទីផ្សារ សកម្មរបស់ឧបករណ៍នោះប្រសិនបើមាន។ ទីផ្សារមួយចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬបំណុល កើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់។

ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេ នោះ ក្រុមហ៊ុនត្រូវប្រើបច្ចេកទេសវាយតម្លៃណា ដែលអាចប្រើប្រាស់ទិន្នន័យដែលអាចអង្កេតបានជាអតិបរមា និងកាត់បន្ថយនូវការប្រើប្រាស់ទិន្នន័យដែលមិនអាចអង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុង ទីផ្សារនឹងពិចារណានៅក្នុងការកំណត់តម្លៃ។

### (vi) ការវាស់វែងតម្លៃសមស្រប (ត)

ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃសមស្រប របស់ឧបករណ៍ហិរញ្ញវត្ថុមួយ នៅពេលទទួលស្គាល់ជាលើកដំបូង ជាទូទៅគឺជាតម្លៃប្រតិបត្តិការ មានន័យថា ជាតម្លៃសមស្របនៃផលតបស្នងបានផ្តល់ឱ្យ ឬបានទទួល។ ប្រសិនបើក្រុមហ៊ុនកំណត់ថា តម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង ខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនេះពុំមានភស្តុតាងមកបញ្ជាក់ តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្មចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃ ដោយប្រើប្រាស់តែទិន្នន័យទីផ្សារដែលអាចអង្កេតបាន ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូង តាមតម្លៃសមស្របដោយកែតម្រូវតាមរយៈ ការពន្យារនូវភាពខុសគ្នារវាងតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង និងតម្លៃប្រតិបត្តិការ។ នាពេលបន្តបន្ទាប់ ភាពខុសគ្នានោះគឺត្រូវទទួលស្គាល់នៅក្នុងចំណេញ ឬខាត ផ្អែកលើមូលដ្ឋានសមរម្យទៅតាមអាយុកាលរបស់ឧបករណ៍នោះ ក៏ប៉ុន្តែមិនឱ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ។

ក្រុមហ៊ុនទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រម តម្លៃសមស្រប នៅចុងការិយបរិច្ឆេទរាយការណ៍អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

### (vii) ការកំណត់អត្តសញ្ញាណ និងការវាស់វែងឱនភាពនៃតម្លៃ

*ភស្តុតាងដែលបញ្ជាក់ថាមានឱនភាពនៃតម្លៃ*

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនវាយតម្លៃថា តើមានភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានកត់ត្រាតាមថ្លៃដើម ឬរំលស់ថ្លៃដើម។ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ នៅពេលដែលមានភស្តុតាងបញ្ជាក់ថា មានព្រឹត្តិការណ៍ខាតបង់មួយ ឬច្រើនបានកើតឡើងបន្ទាប់ពីការទទួលស្គាល់ទ្រព្យសកម្មជាលើកដំបូង ហើយដែលនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើ លំហូរទឹកប្រាក់នាពេលអនាគតនៃទ្រព្យសកម្ម ដែលអាចប៉ាន់ស្មានដោយភាពជឿជាក់បាន។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃ រួមមាន៖

- ការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការខកខានមិនបានសង ឬហួសកាលកំណត់សងរបស់អតិថិជន
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃឥណទាន ដែលក្រុមហ៊ុនមិនបានពិចារណា



## (ខ) ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (vii) ការកំណត់អត្តសញ្ញាណ និងការវាស់វែងឱនភាពនៃតម្លៃ

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃ រួមមាន៖ (ត)

- សញ្ញាណដែលបញ្ជាក់ថាអតិថិជន ឬអ្នកបោះផ្សាយទំនងនឹងជួបប្រទះការក្ស័យធន
- ការបាត់បង់ទីផ្សារសកម្មសម្រាប់មូលបត្រ
- ទិន្នន័យដែលអាចអង្កេតបានពាក់ព័ន្ធ នឹងក្រុមនៃទ្រព្យសកម្ម ដូចជាការផ្លាស់ប្តូរអវិជ្ជមានក្នុងស្ថានភាពនៃការទូទាត់របស់អតិថិជន ឬអ្នកបោះផ្សាយជាក្រុម ឬលក្ខខណ្ឌសេដ្ឋកិច្ចដែលទាក់ទងនឹង ការខកខានមិនបានសងជាក្រុម។

*ការវាយតម្លៃជាលក្ខណៈទោល និងជាក្រុម*

រាល់ទ្រព្យសកម្មសារវន្ត ត្រូវបានវាយតម្លៃជាលក្ខណៈទោលសម្រាប់ឱនភាពនៃតម្លៃ។

ការវាយតម្លៃជាលក្ខណៈទោលដែលត្រូវបានរកឃើញថាមិនមានឱនភាពនៃតម្លៃជាពិសេស ត្រូវបានវាយតម្លៃជាក្រុមសម្រាប់ឱនភាពនៃតម្លៃ ដែលបានកើតឡើងប៉ុន្តែមិនទាន់ទទួលស្គាល់នៅឡើយ។

សមាសធាតុទោលនៃសំវិធានធនសរុបសម្រាប់ ឱនភាពនៃតម្លៃ ត្រូវបានអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាយតម្លៃជាលក្ខណៈទោលនៃឱនភាពនៃតម្លៃ ហើយត្រូវបានរកឃើញថាមានឱនភាពនៃតម្លៃទោល និងផ្អែកតាមការប៉ាន់ស្មានដ៏ប្រសើរបំផុតរបស់អ្នកគ្រប់គ្រងលើ តម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់ ដែលរំពឹងថានឹងទទួលបាន។ ក្នុងការប៉ាន់ស្មានលំហូរទឹកប្រាក់ទាំងនេះ អ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យអំពីស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុល និងតម្លៃសុទ្ធដែលអាចលក់បានចំពោះទ្រព្យបញ្ចាំណាមួយ។ ទ្រព្យសកម្មដែលមានឱនភាពនៃតម្លៃនីមួយៗ ត្រូវបានវាយតម្លៃលើគុណសម្បត្តិរបស់វា ហើយយុទ្ធសាស្ត្រគណនា និងការប៉ាន់ស្មានលំហូរទឹកប្រាក់ដែលអាចប្រមូលបានមកវិញ ត្រូវបានអនុម័តឯករាជ្យដោយអ្នកគ្រប់គ្រង។

សមាសធាតុជាក្រុមនៃសំវិធានធនសរុបត្រូវបានបង្កើតឡើងសម្រាប់៖

- ក្រុមនៃឥណទានដែលមានលក្ខណៈដូចគ្នា ហើយមិនត្រូវបានចាត់ទុកថាជាលក្ខណៈទោលសារវន្ត និង
- ក្រុមនៃទ្រព្យសកម្មដែលមានលក្ខណៈទោលជាសារវន្ត ប៉ុន្តែមិនត្រូវបានរកឃើញថាមាន ឱនភាពនៃតម្លៃទោលនោះទេ។

*ការវាយតម្លៃជាលក្ខណៈទោល និងជាក្រុម*

សំវិធានធនជាក្រុម សម្រាប់ក្រុមនៃឥណទានត្រូវទទួលមានលក្ខណៈដូចគ្នា ត្រូវបានបង្កើតឡើងដោយប្រើវិធីសាស្ត្រស្ថិតិ ដូចជាវិធីសាស្ត្រអត្រាវិលជុំ ឬសម្រាប់ផលប័ត្រតូចៗដែលមិនមានព័ត៌មានគ្រប់គ្រាន់ វិធីសាស្ត្រផ្អែកលើបទពិសោធន៍អត្រាបាត់បង់ប្រវត្តិសាស្ត្រ។

ក្នុងការវាយតម្លៃ សំវិធានធនលើការខាតបង់ជាក្រុម អ្នកគ្រប់គ្រងបានពិចារណាលើកត្តាមួយចំនួន ដូចជាគុណភាពឥណទាន ទំហំផលប័ត្រ ការប្រមូលផ្តុំ និងកត្តាសេដ្ឋកិច្ចជាដើម។ ដើម្បីប៉ាន់ប្រមាណនូវតម្រូវការសំវិធានធន ការសន្មតត្រូវបានធ្វើឡើងដើម្បីកំណត់ពីលក្ខណៈនៃការខាតបង់ ដែលត្រូវបានយកគំរូតាម និងការកំណត់ទិន្នន័យប៉ារ៉ាម៉ែត្រតាមតម្រូវការ ដោយផ្អែកលើបទពិសោធន៍ប្រវត្តិសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន។ ភាពត្រឹមត្រូវនៃសំវិធានធន អាស្រ័យលើការសន្មតនូវគំរូ និងប៉ារ៉ាម៉ែត្រដែលត្រូវបានប្រើប្រាស់ក្នុងការកំណត់សំវិធានធនជាក្រុម។

*ការវាស់វែង*

ការខាតបង់ឱនភាពនៃតម្លៃលើទ្រព្យសកម្មដែលបានវាស់វែងតាមរំលស់ថ្លៃដើម ត្រូវបានគណនាដោយភាពខុសគ្នារវាងតម្លៃយោង និងតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់ដែលបានប៉ាន់ស្មាននាពេលអនាគត ដែលបានធ្វើអប្បហារតាមអត្រាការប្រាក់ប្រសិទ្ធភាពដើមរបស់ទ្រព្យសកម្ម។

*ការទទួលបានមកវិញ និងការលុបចោលឱនភាពនៃតម្លៃ*

អាចទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលកើតឡើង បន្ទាប់ពីឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ ក្រុមហ៊ុនត្រូវធ្វើការកែប្រែលើការខាតបង់ឱនភាពនៃតម្លៃដែលបានទទួលស្គាល់ពីមុនដោយផ្ទាល់ ឬដោយការធ្វើនិយ័តភាព ចំពោះគណនីសវិធានធន។

ការទទួលបានមកវិញ នឹងមិនបណ្តាលឱ្យមានចំនួនតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ក្រោយកាត់កងគណនីសវិធានធន) លើសពីចំនួនតម្លៃយោងដែលមានឱនភាពនៃតម្លៃ ដែលមិនបានទទួលស្គាល់ពីមុននោះទេ។ ក្រុមហ៊ុនត្រូវទទួលស្គាល់ចំនួនទឹកប្រាក់ដែលទទួលបានមកវិញ ក្នុងចំណេញ ឬខាតភ្លាមៗ។

ក្រុមហ៊ុន លុបចោលឥណទានផ្នែកខ្លះ ឬទាំងស្រុង និងសវិធានធនពាក់ព័ន្ធ សម្រាប់ការខាតបង់លើឱនភាពនៃតម្លៃនៅពេលដែលអ្នកគ្រប់គ្រងកំណត់ថា មិនមានលទ្ធភាពជាក់លាក់ក្នុងការប្រមូលបានមកវិញ។

## (ខ) ឧបករណ៍ហិរញ្ញវត្ថុ (ត)

## (គ) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ និងសមតុល្យនៅធនាគារ ប្រាក់បញ្ញើ និងការវិនិយោគរយៈពេលខ្លី ដែលមានកាលវសាននៅពេលតម្កល់ដំបូងមានរយៈពេល ៣ខែ ឬតិចជាង ដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បានដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ និងត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនក្នុងការគ្រប់គ្រងកិច្ចសន្យារយៈពេលខ្លីរបស់ខ្លួន។

សាច់ប្រាក់ និងសាច់ប្រាក់សមមូល ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## (ឃ) សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា

សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ ស្ថានភាពហិរញ្ញវត្ថុ។

## (ង) ប្រាក់តម្កល់តាមច្បាប់

ប្រាក់តម្កល់តាមច្បាប់ សំដៅទៅលើទុនបម្រុងតាមច្បាប់ដែលត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមា ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។ ប្រាក់តម្កល់តាមច្បាប់មិនអាច ប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុនទេ ដូច្នេះវាមិនត្រូវបានចាត់ទុកជាផ្នែកមួយនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូលសម្រាប់គោលបំណងនៃរបាយការណ៍លំហូរទឹកប្រាក់ឡើយ។

ប្រាក់តម្កល់តាមច្បាប់ ត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅ ក្នុងរបាយការណ៍ ស្ថានភាពហិរញ្ញវត្ថុ។

## (ច) ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជន គឺជាទ្រព្យសកម្មហិរញ្ញវត្ថុអនិស្សន្ទដែលអាចទូទាត់បានតាមលក្ខណៈថេរ ឬអាចកំណត់បាន ដែលមិនមែនជាតម្លៃដកស្រង់ពីទីផ្សារសកម្ម ហើយក្រុមហ៊ុនមិនមានបំណងលក់នៅក្នុងពេលបច្ចុប្បន្ន ឬនៅពេលខាងមុខនោះទេ។

ឥណទានផ្តល់ដល់អតិថិជនត្រូវបានវាស់វែងលើកដំបូង តាមតម្លៃសមស្របបូកចំណាយប្រតិបត្តិការដែល កើតឡើងដោយផ្ទាល់ ហើយនាពេលបន្ទាប់ត្រូវកត់ត្រាតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

## (ឆ) ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗទៀត ត្រូវបានវាស់វែងតាមរំលស់ថ្លៃ ដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### (ជ) ទ្រព្យ និងបរិក្ខារ

ផ្នែកនៃទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាតាមតម្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន។ នៅពេលដែលផ្នែកនៃទ្រព្យ និងបរិក្ខារ មានអាយុកាលប្រើប្រាស់ខុសៗគ្នា ផ្នែកទាំងនោះត្រូវបានចាត់ទុកជាផ្នែកផ្សេងគ្នានៃទ្រព្យ និងបរិក្ខារ។

រំលស់លើទ្រព្យ និងបរិក្ខារ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងចំណេញ ឬខាតលើមូលដ្ឋានរំលស់ថេរតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យ និងបរិក្ខារនីមួយៗ ដូចខាងក្រោម៖

| | អាយុកាលប្រើប្រាស់ |
|---|---|
| ការកែលម្អទ្រព្យជួល | ទាបជាងចន្លោះ 10ឆ្នាំឬរយៈពេលជួល |
| យានយន្ត | 6ឆ្នាំ |
| គ្រឿងបំពាក់ ការិយាល័យ | 4ឆ្នាំ |
| បរិក្ខារកុំព្យូទ័រ | 4ឆ្នាំ |
| គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ | 4ឆ្នាំ |

ទ្រព្យកំពុងបង្កើត មិនត្រូវបានរំលស់នោះទេ រហូតដល់ពេលទ្រព្យសកម្មដែលពាក់ព័ន្ធនោះត្រូវបានបញ្ចប់ និងដាក់ឱ្យប្រើប្រាស់ក្នុងប្រតិបត្តិការ។

ចំណាយបន្តបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យ និងបរិក្ខារ ដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគតដល់ក្រុមហ៊ុនលើសពីស្តង់ដាដើម។ រាល់ចំណាយបន្តបន្ទាប់ផ្សេងៗទៀត ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

ចំណេញ ឬខាតពីការឈប់ប្រើប្រាស់ ឬការលក់ចេញផ្នែកនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលបានពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាតនៅពេលដែលឈប់ប្រើប្រាស់ ឬលក់ចេញ។

ទ្រព្យ និងបរិក្ខារ ដែលបានដករំលស់អស់ហើយ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ពេល ដែលទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានលក់ចេញ ឬលុបចោល។

### (ឈ) ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី ដែលរួមមានកុំព្យូទ័រសូហ្វវែរ ត្រូវបានវាស់វែងតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន។ ទ្រព្យសកម្មអរូបី ត្រូវបានរំលស់តាមអត្រា 20% ក្នុងមួយឆ្នាំ ដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរ។

ថ្លៃដើមដែលបានកើតឡើងក្នុងការរៀបចំផែនការ ឬវាយតម្លៃសំណើសូហ្វវែរ ឬក្នុងការថែទាំប្រព័ន្ធបន្ទាប់ពីដាក់ឱ្យដំណើរការ មិនត្រូវបានទទួលស្គាល់ទេ។

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ ត្រូវបានវាយតម្លៃនាចុងការិយបរិច្ឆេទនៃរបាយការណ៍ និងធ្វើនិយ័តភាពប្រសិនបើសមស្រប។

### (ញ) ឱនភាពនៃតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យនៃសកម្មមិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុន (ក្រៅពីពន្ធពន្យារជាទ្រព្យសកម្ម) ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថា តើមានសញ្ញាណណាមួយដែលបង្ហាញថាទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង ការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលបានមកវិញរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង។

តម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយដើម្បីលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់ ការប៉ាន់ស្មានលំហូរទឹកប្រាក់នាពេលអនាគត ត្រូវបានធ្វើអប្បហារមកតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ។ សម្រាប់គោលបំណងនៃការធ្វើតេស្តលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗ ដែលអាចបង្កើតសាច់ប្រាក់បានពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់។

ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្មមួយ ឬឯកតា បង្កើតសាច់ប្រាក់មានចំនួនលើសពីតម្លៃដែលអាចប្រមូលមកបានវិញ។ ការខាត បង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ជា ក្នុងចំណេញ ឬខាត។

### (ដ) ប្រាក់កម្ចី និងបំណុលផ្សេងៗ

ប្រាក់កម្ចី និងបំណុលផ្សេងៗ ត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើមដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### (ឋ) សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយវាមានលទ្ធភាពដែលតម្រូវឱ្យមានលំហូរចេញ នូវអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ។ ប្រសិនបើ ផលប៉ះពាល់មានលក្ខណៈជាសារវន្ត សំវិធានធនត្រូវបានកំណត់ដោយអប្បហារលំហូរ ទឹកប្រាក់ដែលរំពឹងថានឹងត្រូវទូទាត់នាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មាននៃតម្លៃពេលវេលា ក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។ អប្បហារនៅសល់ត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញប្បទាន។

### (ឌ) អត្ថប្រយោជន៍និយោជិត

#### (i) អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី ត្រូវបានចំណាយនៅពេលដែលសេវាកម្មត្រូវបានផ្តល់ជូន។ ចំនួនដែលរំពឹងទុកថានឹងត្រូវចំណាយ ត្រូវបានទទួលស្គាល់ជាបំណុល ប្រសិនបើក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ក្នុងការទូទាត់ចំណាយ ដែលជាលទ្ធផលនៃការងារដែលបានបំពេញរួចមកហើយដោយនិយោជិត ហើយកាតព្វកិច្ចនោះអាចធ្វើការប៉ាន់ស្មានបានដោយភាពជឿជាក់។

#### (ii) ផែនការវិភាគទានដែលបានកំណត់ - មូលនិធិសោធននិវត្តន៍

កាតព្វកិច្ចសម្រាប់ការរួមចំណែក ចំពោះផែនការវិភាគទានដែលបានកំណត់ត្រូវបានចំណាយជាសេវាកម្ម ពាក់ព័ន្ធបានបំពេញ និងត្រូវបានទទួលស្គាល់ជាចំណាយលើបុគ្គលិកនៅក្នុងចំណេញ ឬខាត។ ការរួមចំណែកដែលបានបង់មុនត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម របៀតដល់សាច់ប្រាក់ត្រូវបានបង្វិល មកវិញ ឬមានការដកចេញពីការទូទាត់នាពេលអនាគត។

### (iii) អត្ថប្រយោជន៍និយោជិតរយៈពេលវែង

កាតព្វកិច្ចរបស់ក្រុមហ៊ុនចំពោះអត្ថប្រយោជន៍ និយោជិតរយៈពេលវែង គឺជាចំណាយលើអត្ថប្រយោជន៍ ដែលនិយោជិតត្រូវទទួលបាន ពីការបំពេញការងារក្នុងការិយបរិច្ឆេទកន្លងផុតទៅ និងបច្ចុប្បន្ន។ អត្ថប្រយោជន៍ និយោជិតរយៈពេលវែង ត្រូវបានធ្វើអប្បហារទៅតម្លៃបច្ចុប្បន្ន។ ការវាស់វែងសារជាថ្មីត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត នៅក្នុងការិយបរិច្ឆេទដែលចំណាយនេះបានកើតឡើង។

### (ឍ) ដើមទុន

ថ្លៃដើមផ្ទាល់ដែលទាក់ទងនឹងការបោះផ្សាយ ឧបករណ៍មូលធន ត្រូវបានទទួលស្គាល់ជាការកាត់កងចេញ ពីឧបករណ៍មូលធនដែលបានវាស់វែងលើកដំបូង។

### (ណ) ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិ ត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នា រវាងឥណទានមានឱនភាពនៃតម្លៃ ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និងសំវិធានធនតាមបទប្បញ្ញត្តិស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-017-344 ចុះថ្ងៃទី1 ខែធ្នូ ឆ្នាំ2017 និងសារាចរណែនាំ លេខ ធ7-018-001 ស.រ.ច.ណ ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើឱនភាពនៃតម្លៃ សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

### (ណ) ទុនបម្រុងតាមបទប្បញ្ញត្តិ (ត)

យោងតាម គោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា រាល់ឥណទានផ្តល់ដល់អតិថិជនត្រូវធ្វើចំណាត់ថ្នាក់តាមសមត្ថភាពសងរបស់អ្នកខ្ចី និងចំនួនថ្ងៃដែលហួសកំណត់ដូចខាងក្រោម៖(ត)

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលហួសកាលកំណត់សង | អត្រាសំវិធានធន |
|---|---|---|
| **ឥណទានរយៈពេលខ្លី (តិចជាង ឬស្មើមួយឆ្នាំ)៖** | | |
| ឥណទានធម្មតា/ស្តង់ដា | <15ថ្ងៃ | 1% |
| ឥណទានឃ្លាំមើល | 15ថ្ងៃ ដល់ 30ថ្ងៃ | 3% |
| ឥណទានក្រោមស្តង់ដា | 31ថ្ងៃ ដល់ 60ថ្ងៃ | 20% |
| ឥណទានជាប់សង្ស័យ | 61ថ្ងៃ ដល់ 90ថ្ងៃ | 50% |
| ឥណទានបាត់បង់ | ≥91ថ្ងៃ | 100% |
| **ឥណទានរយៈពេលវែង (ច្រើនជាងមួយឆ្នាំ)៖** | | |
| ឥណទានធម្មតា/ស្តង់ដា | <30ថ្ងៃ | 1% |
| ឥណទានឃ្លាំមើល | ≥30ថ្ងៃ ដល់ 89ថ្ងៃ | 3% |
| ឥណទានក្រោមស្តង់ដា | ≥90ថ្ងៃ ដល់ 179ថ្ងៃ | 20% |
| ឥណទានជាប់សង្ស័យ | ≥180ថ្ងៃ ដល់ 359ថ្ងៃ | 50% |
| ឥណទានបាត់បង់ | 359ថ្ងៃឬ ច្រើនជាងនេះ | 100% |

ដោយអនុលោមតាមប្រកាស ក្រុមហ៊ុនត្រូវប្រៀបធៀបសំវិធានធន ដែលគណនាតាមតម្រូវការខាងលើជាមួយនឹងសំវិធានធន ដែលគណនាតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យមៈ

(i) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិទាបជាង នោះក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធន អនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ឬ

(ii) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិខ្ពស់ជាង នោះក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធន ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និងផ្ទេរចំនួនលម្អៀងនោះពីប្រាក់ចំណេញរក្សាទុក ឬប្រាក់ខាតបង្គរទៅទុនបម្រុងតាម បទប្បញ្ញត្តិនៅក្នុងគណនីមូលធន។

ទុនបម្រុងបទប្បញ្ញត្តិ មិនមែនជាប្រភេទដែលត្រូវបញ្ចូលក្នុងការគណនាទ្រព្យសម្បត្តិសុទ្ធរបស់ក្រុមហ៊ុននោះទេ។

### (ត) ការប្រាក់

ចំណូលពីការប្រាក់ និងចំណាយលើការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ វិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព គឺជាវិធីសាស្ត្រនៃការគណនាតម្លៃរំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ និងបែងចែកចំណូលការប្រាក់ ឬចំណាយការប្រាក់ទៅតាមរយៈពេលដែលពាក់ព័ន្ធ។ "អត្រាការប្រាក់ប្រសិទ្ធភាព" គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានឹងទូទាត់ ឬនឹងត្រូវទទួល តាមរយៈអាយុកាលរំពឹងទុករបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ (ឬ រយៈពេលខ្លីជាងប្រសិនបើសមស្រប) ទៅតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុនោះ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព ក្រុមហ៊ុនធ្វើការប៉ាន់ស្មានលើលំហូរទឹកប្រាក់ នាពេលអនាគតដោយពិចារណារាល់លក្ខខណ្ឌទាំងអស់ របស់កិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវការខាតបង់ឥណទានរំពឹងទុកនាពេលអនាគតនោះទេ។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាព រួមបញ្ចូលនូវថ្លៃដើមប្រតិបត្តិការ និងកម្រៃទាំងអស់ដែលបានបង់ ឬបានទទួលដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព។ ថ្លៃដើមប្រតិបត្តិការរួមមាន ការចំណាយបន្ថែម ដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬការបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

### (ថ) កម្រៃ និងកម្រៃជើងសា

ចំណូល និងចំណាយកម្រៃ និងជើងសា ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលទៅក្នុងការវាស់វែងអត្រាការប្រាក់ប្រសិទ្ធភាព។

ចំណូលកម្រៃ និងជើងសាផ្សេងទៀត ត្រូវបានទទួលស្គាល់នៅពេលបានបំពេញសេវាកម្ម។ ប្រសិនបើការសន្យាផ្តល់ឥណទាន មិនត្រូវបានរំពឹងថានឹងមានលទ្ធផលក្នុងការដកប្រាក់នោះ កម្រៃពីការសន្យាផ្តល់ឥណទានពាក់ព័ន្ធត្រូវបានទទួលស្គាល់ដោយ ផ្អែកលើមូលដ្ឋានរំលស់ថេរទៅតាមថេរវេលានៃកិច្ចសន្យា។

ចំណាយកម្រៃ និងជើងសាផ្សេងៗ ពាក់ព័ន្ធជាចម្បងលើកម្រៃប្រតិបត្តិការ និងសេវាកម្ម ត្រូវបានចំណាយនៅពេលសេវាកម្មត្រូវបានទទួល។

### (ទ) ភតិសន្យា

ភតិសន្យា ត្រូវបានចាត់ថ្នាក់ជាភតិសន្យាហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌនៃភតិសន្យា ផ្ទេររាល់ហានិភ័យ និងអត្ថប្រយោជន៍នៃកម្មសិទ្ធិ នៃទ្រព្យទាំងអស់ឱ្យស្ថិតនៅក្រោមក្រុមហ៊ុន។ ភតិសន្យាផ្សេងៗទៀត គឺត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិការ។

ការទូទាត់ភតិសន្យាដែលធ្វើឡើងក្រោមភតិសន្យាប្រតិបត្តិការត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាតតាមមូលដ្ឋានថេរទៅតាមរយៈពេលនៃការជួល។ ប្រាក់លើកទឹកចិត្តភតិសន្យាដែលបានទទួល ត្រូវបានទទួលស្គាល់ថាជាផ្នែកមួយនៃចំណាយភតិសន្យាសរុបក្នុងរយៈពេលនៃការជួល។

### (ធ) ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញ រួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ វាត្រូវបានទទួលស្គាល់នៅក្នុង ចំណេញ ឬខាត លើកលែងតែធាតុណាបានទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន ឬនៅក្នុងលទ្ធផលលម្អិតផ្សេងៗ។

### (i) ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថា ត្រូវបង់ ឬត្រូវទទួលលើប្រាក់ចំណេញ ឬខាតជាប់ពន្ធ ប្រចាំឆ្នាំ និងនិយ័តភាពលើពន្ធដែលត្រូវបង់ ឬត្រូវទទួលដែលទាក់ទងទៅនឹងការិយបរិច្ឆេទមុនៗ។ ចំនួននពន្ធដែលត្រូវបង់ ឬត្រូវទទួលប្រចាំឆ្នាំ គឺជាការប៉ាន់ស្មានដ៏ល្អបំផុតនៃចំនួនពន្ធដែលរំពឹងថានឹងត្រូវបង់ ឬ ត្រូវទទួលដែលឆ្លុះបញ្ចាំងពីភាពមិនច្បាស់លាស់ទាក់ទងនឹងពន្ធលើប្រាក់ចំណេញ ប្រសិនបើមាន។ វាត្រូវបានវាស់វែងដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍។

### (ii) ពន្ធពន្យារ

ពន្ធពន្យារ ត្រូវបានទទួលស្គាល់លើភាពលម្អៀងជាបណ្តោះអាសន្នរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់សម្រាប់ការខាតពន្ធមិនបានប្រើប្រាស់ ឥណទានពន្ធមិនបានប្រើប្រាស់ និងភាពលម្អៀងជាបណ្តោះអាសន្នដែលអាចកាត់កងបាន តែក្នុងករណីអាចនឹងកើតមានឡើង លើប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតដែលអាចប្រើប្រាស់បាន។ ប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតត្រូវបានកំណត់ដោយ ផ្អែកលើផែនការអាជីវកម្មរបស់ក្រុមហ៊ុន និងភាពខុសគ្នាបណ្តោះអាសន្នពីចំនួនដែលទទួលបានមកវិញ។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរាល់កាលបរិច្ឆេទរាយការណ៍ ហើយត្រូវបានកាត់បន្ថយក្នុងករណីដែល វាមិនអាចកើតឡើងនូវអត្ថប្រយោជន៍ពន្ធដែលពាក់ព័ន្ធដែលអាចនឹងប្រើប្រាស់បាន។

ពន្ធពន្យារជាទ្រព្យសកម្មដែលមិនបានទទួលស្គាល់ ត្រូវបានវាយតម្លៃឡើងវិញនៅកាលបរិច្ឆេទរាយការណ៍នីមួយៗ និងត្រូវបានទទួលស្គាល់តែក្នុងករណីដែលអាចនឹងកើតមានឡើងនូវអត្ថប្រយោជន៍ជាប់ពន្ធនាពេលអនាគត ដែលអាចប្រើប្រាស់បាន។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានកំណត់ដោយប្រើអត្រាពន្ធដែលរំពឹងថានឹងប្រើលើភាពលម្អៀងជាបណ្តោះអាសន្នដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍។

ការវាស់វែងពន្ធពន្យារឆ្លុះបញ្ចាំងពីលទ្ធផល ដែលក្រុមហ៊ុនរំពឹងថា (នៅកាលបរិច្ឆេទរាយការណ៍) នឹងទទួលបានមកវិញ ឬការកាត់កងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល។

ពន្ធពន្យារជាទ្រព្យសកម្ម និងបំណុលពន្ធពន្យារ អាចកាត់កងគ្នាបាន ក្នុងករណីច្បាប់បានអនុញ្ញាត ហើយមានការទាក់ទងនឹងពន្ធលើប្រាក់ចំណេញដែលបានកំណត់ ដោយអាជ្ញាធរពន្ធលើស្ថាប័នតែមួយ ឬលើអង្គភាពពន្ធតែមួយដើម្បីទូទាត់បំណុលពន្ធប្រចាំឆ្នាំ និងទ្រព្យសកម្ម ឬពន្ធពន្យារជាទ្រព្យសកម្ម និងបំណុលពន្ធពន្យារនឹងត្រូវបានទទួលស្គាល់ក្នុងពេលដំណាលគ្នា។

## ៣២. ព័ត៌មានប្រៀបធៀប

ក្នុងអំឡុងពេលនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 អ្នកគ្រប់គ្រងបានរកឃើញនូវកំហុសឆ្គងក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទមុន លើចំណុចដូចខាងក្រោម៖

ក. សាច់ប្រាក់ក្នុងដៃ និងគណនីត្រូវទូទាត់ឱ្យសម្ព័ន្ធញាតិ
ខ. កំហុសឆ្គងក្នុងការកត់ត្រានិយ័តកម្មលើស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម
គ. ការប្តូររូបិយប័ណ្ណបរទេស
ឃ. កំហុសឆ្គងក្នុងការកត់ត្រាថ្លៃដើម និងរំលស់បង្គរលើទ្រព្យ និងបរិក្ខារ
ង. ការកត់ត្រាខ្វះនៃប្រាក់រង្វាន់បង្គរ
ច. កំហុសឆ្គងក្នុងការកត់ត្រាការប្រមូលបានមកវិញពីឥណទានដែលបានលុបចេញពីបញ្ជី
ឆ. ពន្ធលើប្រាក់ចំណេញ និងពន្ធពន្យារ និង
ជ. កំហុសឆ្គងក្នុងការកត់ត្រាទុនបម្រុងតាមបទប្បញ្ញត្តិ។

សេចក្តីលម្អិតលើនិយ័តកម្ម មានដូចខាងក្រោម៖

### ក. សាច់ប្រាក់ក្នុងដៃ និងគណនីត្រូវទូទាត់ឲ្យសម្ព័ន្ធញាតិ

សាច់ប្រាក់រក្សាទុកជំនួសឱ្យ អេស៊ា ឃែស អិចប្រេស ម.ក ដែលជាសម្ព័ន្ធញាតិ នាកាលបរិច្ឆេទរាយកាណ៍ពីមុនបានកត់ត្រាក្រៅតារាងតុល្យការ ជាជាងកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ជាលទ្ធផល គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងឆ្នាំ2020 សាច់ប្រាក់ក្នុងដៃ និងគណនីត្រូវទូទាត់ឱ្យសម្ព័ន្ធញាតិត្រូវបានកត់ខ្វះចំនួន 48,005 ដុល្លារអាមេរិក និង 5,085 ដុល្លារអាមេរិក រៀងគ្នា។

### ខ. កំហុសឆ្គងក្នុងការកត់ត្រានិយ័តកម្មលើស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម

កំណត់ត្រាគណនេយ្យរបស់ក្រុមហ៊ុនត្រូវបានអនុវត្តដំបូងតាមស្តង់ដាគណនេយ្យកម្ពុជា (“CAS”) ជាមួយនឹងការធ្វើនិយ័តកម្មទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម។ ក្នុងអំឡុងពេលនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 អ្នកគ្រប់គ្រងបានរកឃើញកំហុសឆ្គងក្នុងការធ្វើនិយ័តកម្មទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំមុនដូចខាងក្រោម៖

*(i) កំហុសឆ្គងក្នុងការកត់ត្រាសមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា*

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា បានកត់ត្រាលើសចំនួន 1,820 ដុល្លារអាមេរិក ព្រមទាំងការកត់ត្រាខ្វះនូវការខាតបង់ឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ចំនួន 1,820 ដុល្លារអាមេរិក។

ការកត់ត្រាខុសនេះ បណ្តាលមកពីកំហុសឆ្គងក្នុងទទួលស្គាល់ការខាតបង់ឱនភាពនៃតម្លៃលើសមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា។

*(ii) កំហុសឆ្គងក្នុងការកត់ត្រាឥណទានផ្តល់ដល់អតិថិជន និងចំណូលការប្រាក់*

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ឥណទានផ្តល់ដល់អតិថិជន និងប្រាក់ចំណូលការប្រាក់ បានកត់ត្រាខ្វះ ចំនួន 125,127 ដុល្លារអាមេរិក។

ការកត់ត្រាខុសនេះ បណ្តាលមកពីកំហុសឆ្គងក្នុងការទទួលស្គាល់ប្រាក់កម្រៃឥណទាន ដែលជាផ្នែកមួយនៃអត្រាការប្រាក់ប្រសិទ្ធភាព។

*(iii) ការខាតបង់លើឱនភាពនៃតម្លៃសុទ្ធលើឥណទានផ្តល់ដល់អតិថិជន*

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ឥណទានផ្តល់ដល់អតិថិជនត្រូវបានកត់ត្រាលើស និងការខាតបង់ឱនភាពនៃតម្លៃសុទ្ធលើឥណទានផ្តល់ដល់អតិថិជនបានកត់ត្រាខ្វះចំនួន 73,563 ដុល្លារអាមេរិកសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021។

ការកត់ត្រាខុសនេះ បណ្តាលមកពីកំហុសឆ្គងក្នុងការទទួលស្គាល់លើការខាតបង់ឱនភាពនៃតម្លៃលើឥណទានផ្តល់ដល់អតិថិជន។

*(iv) កំហុសឆ្គងក្នុងការកត់ត្រាប្រាក់កម្ចី និងចំណាយការប្រាក់*

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ប្រាក់កម្ចី និងចំណាយការប្រាក់ ត្រូវបានកត់ត្រាខ្វះចំនួន 88,539 ដុល្លារអាមេរិក។

ការកត់ត្រាខុសនេះ បណ្តាលមកពីកំហុសឆ្គងក្នុងការទទួលស្គាល់ប្រាក់កម្ចី និងកម្រៃលើប្រាក់កម្ចី ដែលជាផ្នែកមួយនៃអត្រាការប្រាក់ប្រសិទ្ធភាព។

## គ. ការប្តូរអត្រារូបិយប័ណ្ណបរទេស។

អនុលោមតាមផ្នែកទី 30.9 នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម នៅចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ ធាតុមិនមែនរូបិយវត្ថុ ដែលត្រូវបានវាស់វែងផ្អែកលើថ្លៃប្រវត្តិសាស្ត្រជារូបិយប័ណ្ណបរទេសត្រូវបានប្តូរដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនៃប្រតិបត្តិការ។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណ ជាទូទៅ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។ ក៏ប៉ុន្តែក្រុមហ៊ុនទទួលស្គាល់ភាពលម្អៀងពីការប្តូររូបិយប័ណ្ណនៅក្នុងខ្ទង់ 'ទ្រព្យសកម្មផ្សេងៗ' នៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ជាលទ្ធផល នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ទ្រព្យសកម្មផ្សេងៗ និងចំណាយប្រតិបត្តិការផ្សេងៗបានកត់ត្រាលើស និងខ្វះចំនួន 15,964 ដុល្លារអាមេរិក រៀងគ្នា។

## ឃ. កំហុសឆ្គងក្នុងការកត់ត្រាថ្លៃដើម និងរំលស់បង្គរលើទ្រព្យ និងបរិក្ខារ

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ថ្លៃដើម និងរំលស់បង្គរលើទ្រព្យ និងបរិក្ខារបានកត់ត្រាលើសចំនួន 4,383 ដុល្លារអាមេរិក ។ ផលប៉ះពាល់សុទ្ធចំពោះរបាយការណ៍ហិរញ្ញវត្ថុគឺសូន្យ។

### ង. ការកត់ត្រាខ្វះនៃប្រាក់រង្វាន់បង្គរ

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ក្រុមហ៊ុនបានរកឃើញថា ប្រាក់រង្វាន់បង្គរត្រូវបានកត់ត្រាខ្វះចំនួន 174,012 ដុល្លារអាមេរិក។ ជាលទ្ធផល ចំណាយបុគ្គលិកអំឡុងការិយបរិច្ឆេទ 2021 ត្រូវបានកត់ត្រាខ្វះចំនួន 174,012 ដុល្លារអាមេរិក ដូចគ្នាដែរ។

### ច. កំហុសឆ្គងក្នុងការកត់ត្រាការប្រមូលបានមកវិញពីឥណទានដែលបានលុបចេញពីបញ្ជី

ក្នុងការិយបរិច្ឆេទឆ្នាំ2021 ការប្រមូលបានមកវិញពីឥណទានដែលបានលុបចេញពីបញ្ជីមានចំនួន 11,235 ដុល្លារអាមេរិក ត្រូវបានកត់ត្រាខុសនៅក្នុងការខាតបង់ឱនភាពនៃតម្លៃសុទ្ធលើឧបករណ៍ហិរញ្ញវត្ថុ។

### ឆ. ពន្ធលើប្រាក់ចំណេញ និងពន្ធពន្យារ

ជាលទ្ធផលនៃផ្នែក ខ គ និង ឃ ខាងលើ ពន្ធពន្យារជាទ្រព្យសកម្ម និងបំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំបានកត់ត្រាលើស និងខ្វះចំនួន 7,757 ដុល្លារអាមេរិក និង 76,835 ដុល្លារអាមេរិក រៀងគ្នា។ ចំណាយពន្ធលើប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 បានកត់ត្រាលើសចំនួន 69,078 ដុល្លារអាមេរិក។

### ជ. កំហុសក្នុងការកត់ត្រាទុនបម្រុងតាមបទប្បញ្ញត្តិ

ជាលទ្ធផលនៃផ្នែក ខ និង គ ខាងលើ ទុនបម្រុងតាមបទប្បញ្ញត្តិ ត្រូវបានកត់ត្រាលើសចំនួន 212,071 ដុល្លារអាមេរិក ស្របពេលដែលប្រាក់ចំណេញរក្សាទុកត្រូវបានកត់ត្រាលើសចំនួន 212,071 ដុល្លារអាមេរិក នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021។

# ៣២. ព័ត៌មានប្រៀបធៀប (ត)

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងសេចក្តីសង្ខេបនៃធាតុ ដែលរងផលប៉ះពាល់ដោយការរាយការណ៍ឡើងវិញនៃព័ត៌មានប្រៀបធៀប និងការកែតម្រូវកំហុសឆ្គងទាំងនោះមានដូចខាងក្រោម៖

| | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | | | | | ថ្ងៃទី1 ខែមករា ឆ្នាំ2021 | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ធាតុ | ដូចដែលបាន រាយការណ៍ពីមុន ដុល្លារអាមេរិក | ការចាត់ចំណាត់ថ្នាក់ ឡើងវិញ ដុល្លារអាមេរិក | និយ័តកម្ម ដុល្លារអាមេរិក | ដូចដែល រាយការណ៍ឡើងវិញ ដុល្លារអាមេរិក | ដូចដែល រាយការណ៍ឡើងវិញ ពាន់រៀល (កំណត់សម្គាល់ 5) | ដូចដែលបាន រាយការណ៍ពីមុន ដុល្លារអាមេរិក | ការចាត់ចំណាត់ថ្នាក់ ឡើងវិញ ដុល្លារអាមេរិក | និយ័តកម្ម ដុល្លារអាមេរិក | ដូចដែល រាយការណ៍ឡើងវិញ ដុល្លារអាមេរិក | ដូចដែល រាយការណ៍ឡើងវិញ ពាន់រៀល (កំណត់សម្គាល់ 5) |
| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** | | | | | | | | | | | |
| **ទ្រព្យសកម្ម** | | | | | | | | | | | |
| សាច់ប្រាក់នៅក្នុងដៃ | ក | 445 | - | 48,005 | 48,450 | 197,385 | 4,944 | - | 5,085 | 10,029 | 40,567 |
| សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានហិរញ្ញវត្ថុនានា | | 3,193,348 | (3,193,348) | - | - | - | 3,321,788 | (3,321,788) | - | - | - |
| សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា | | - | 760,351 | - | 760,351 | 3,097,670 | - | 759,996 | - | 759,996 | 3,074,184 |
| សមតុល្យជាមួយធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា | ខ(i) | - | 2,432,997 | (1,820) | 2,431,177 | 9,904,615 | - | 2,561,792 | - | 2,561,792 | 10,362,448 |
| ឥណទានផ្តល់ដល់អតិថិជន | ខ(ii),(iii) | 23,208,743 | - | 51,564 | 23,260,307 | 94,762,491 | 26,098,982 | - | - | 26,098,982 | 105,570,382 |
| ទ្រព្យសកម្មផ្សេងៗ | គ | 38,864 | - | (15,964) | 22,900 | 93,294 | 22,208 | - | - | 22,208 | 89,831 |
| ទ្រព្យ និងបរិក្ខារ | ឃ | 351,723 | - | - | 351,723 | 1,432,920 | 464,510 | - | - | 464,510 | 1,878,943 |
| ទ្រព្យសកម្មអរូបី | | 8,040 | - | - | 8,040 | 32,755 | 9,159 | - | - | 9,159 | 37,048 |
| ពន្ធពន្យារជាទ្រព្យសកម្ម | ង | 67,430 | - | (7,757) | 59,673 | 243,108 | 47,228 | - | - | 47,228 | 191,037 |
| **ទ្រព្យសកម្មសរុប** | | 26,868,593 | - | 74,028 | 26,942,621 | 109,764,238 | 29,968,819 | - | 5,085 | 29,973,904 | 121,244,440 |

ការចាត់ថ្នាក់ឡើងវិញគឺដើម្បីអនុលោមតាមបទបង្ហាញប្រចាំឆ្នាំ។

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងសេចក្តីសង្ខេបនៃធាតុ ដែលរងផលប៉ះពាល់ដោយការរាយការណ៍ឡើងវិញនៃព័ត៌មានប្រៀបធៀប និងការកែតម្រូវកំហុសឆ្គងទាំងនោះមានដូចខាងក្រោម៖ (ត)

| | ធាតុ | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | | | | | ថ្ងៃទី1 ខែមករា ឆ្នាំ2021 | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ដូចដែលបាន រាយការណ៍ពីមុន ដុល្លារអាមេរិក | ការចាត់ចំណាត់ ថ្នាក់ឡើងវិញ ដុល្លារអាមេរិក | និយ័តកម្ម ដុល្លារអាមេរិក | ដូចដែល រាយការណ៍ឡើងវិញ ដុល្លារអាមេរិក | ដូចដែល រាយការណ៍ឡើងវិញ ពាន់រៀល (កំណត់សម្គាល់ 5) | ដូចដែលបាន រាយការណ៍ពីមុន ដុល្លារអាមេរិក | ការចាត់ចំណាត់ ថ្នាក់ឡើងវិញ ដុល្លារអាមេរិក | និយ័តកម្ម ដុល្លារអាមេរិក | ដូចដែល រាយការណ៍ឡើងវិញ ដុល្លារអាមេរិក | ដូចដែល រាយការណ៍ឡើងវិញ ពាន់រៀល (កំណត់សម្គាល់ 5) |
| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** | | | | | | | | | | | |
| **បំណុល និងមូលធន** | | | | | | | | | | | |
| **បំណុល** | | | | | | | | | | | |
| ប្រាក់កម្ចី | ខ(iv) | 6,373,380 | - | 88,539 | 6,461,919 | 26,325,858 | 9,799,829 | - | - | 9,799,829 | 39,640,306 |
| កាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | | 12,175 | - | - | 12,175 | 49,601 | 15,525 | - | - | 15,525 | 62,799 |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | ឆ | 131,905 | - | (76,835) | 55,070 | 224,355 | 149,179 | - | - | 149,179 | 603,429 |
| បំណុលផ្សេងៗ | ក ង | 251,825 | - | 222,017 | 473,842 | 1,930,432 | 413,142 | - | 5,085 | 418,227 | 1,691,728 |
| **បំណុលសរុប** | | 6,769,285 | - | 233,721 | 7,003,006 | 28,530,246 | 10,377,675 | - | 5,085 | 10,382,760 | 41,998,262 |
| **មូលធន** | | | | | | | | | | | |
| ដើមទុន | | 15,000,000 | - | - | 15,000,000 | 60,675,000 | 15,000,000 | - | - | 15,000,000 | 60,675,000 |
| វិភាគទានដើមទុន | | 1,373,774 | - | - | 1,373,774 | 5,556,916 | 1,373,774 | - | - | 1,373,774 | 5,556,916 |
| ទុនបម្រុងបទប្បញ្ញត្តិ | ជ | 419,018 | - | (212,071) | 206,947 | 844,588 | 236,978 | - | - | 236,978 | 958,576 |
| ប្រាក់ចំណេញរក្សាទុក | ខ គ ង ឆ ជ | 3,306,516 | - | 52,378 | 3,358,894 | 13,689,488 | 2,980,392 | - | - | 2,980,392 | 12,055,686 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | - | 468,000 | - | - | - | - | - |
| **មូលធនសរុប** | | 20,099,308 | - | (159,693) | 19,939,615 | 81,233,992 | 19,591,144 | - | - | 19,591,144 | 79,246,178 |
| **បំណុល និងមូលធនសរុប** | | 26,868,593 | - | 74,028 | 26,942,621 | 109,764,238 | 29,968,819 | - | 5,085 | 29,973,904 | 121,244,440 |

## ៣២. ព័ត៌មានប្រៀបធៀប (ត)

របាយការណ៍លទ្ធផលលម្អិត និងសេចក្តីសង្ខេបនៃធាតុ ដែលរងផលប៉ះពាល់ដោយការរាយការណ៍ឡើងវិញនៃព័ត៌មានប្រៀបធៀប និងការកែតម្រូវកំហុសដូចដែលសង្ខេបខាងលើមានដូចខាងក្រោម៖

**របាយការណ៍លទ្ធផលលម្អិត**

| | | ឆ្នាំ2021 | | | |
|---|---|---|---|---|---|
| | ធាតុ | ដូចដែលបាន រាយការណ៍ពីមុន ដុល្លារអាមេរិក | និយ័តកម្ម ដុល្លារអាមេរិក | ដូចដែល រាយការណ៍ឡើងវិញ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ចំណូលការប្រាក់ | ខ(ii) | 3,936,438 | 125,127 | 4,061,565 | 16,522,446 |
| ចំណាយការប្រាក់ | ខ(iv) | (648,747) | (88,539) | (737,286) | (2,999,279) |
| **ចំណូលការប្រាក់សុទ្ធ** | | 3,287,691 | 36,588 | 3,324,279 | 13,523,167 |
| ចំណូលកម្រៃជើងសា និង ប្រាក់កម្រៃ | | 6,249 | - | 6,249 | 25,421 |
| ចំណាយកម្រៃជើងសា និង ប្រាក់កម្រៃ | | (7,920) | - | (7,920) | (32,219) |
| **ចំណាយ/(ចំណាយ)កម្រៃជើងសា និងប្រាក់កម្រៃសុទ្ធ** | | (1,671) | - | (1,671) | (6,798) |
| ចំណូលផ្សេងៗ | គ ច | 25,794 | (4,729) | 21,065 | 85,693 |
| **ប្រាក់ចំណូលប្រតិបត្តិការសុទ្ធ** | | 3,311,814 | 31,859 | 3,343,673 | 13,602,062 |
| ការខាតបង់ឱនភាពនៃតម្លៃ លើឧបករណ៍ហិរញ្ញវត្ថុសុទ្ធ | ខ(i) ខ(iii) ច | (41,213) | (86,618) | (127,831) | (520,017) |
| ចំណាយបុគ្គលិក | ង | (1,919,265) | (174,012) | (2,093,277) | (8,515,451) |
| រំលស់ | | (138,183) | - | (138,183) | (562,128) |
| ចំណាយប្រតិបត្តិការផ្សេងៗ | | (555,413) | - | (555,413) | (2,259,420) |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | | 657,740 | (228,771) | 428,969 | 1,745,046 |
| ចំណាយពន្ធលើប្រាក់ចំណេញ | ជ | (149,576) | 69,078 | (80,498) | (327,466) |
| **ប្រាក់ចំណេញសុទ្ធ សម្រាប់ការិយបរិច្ឆេទ** | | 508,164 | (159,693) | 348,471 | 1,417,580 |

របាយការណ៍លំហូរទឹកប្រាក់ និងសេចក្តីសង្ខេបនៃធាតុ ដែលរងផលប៉ះពាល់ដោយការរាយការណ៍ឡើងវិញនៃព័ត៌មានប្រៀបធៀប និងការកែតម្រូវកំហុសដូចដែលសង្ខេបខាងលើមានដូចខាងក្រោម៖

## របាយការណ៍លំហូរទឹកប្រាក់

| | ឆ្នាំ2021 | | | |
|---|---|---|---|---|
| | ដូចដែលបាន រាយការណ៍ពីមុន | និយ័តកម្ម | ដូចដែល រាយការណ៍ឡើងវិញ | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | 508,164 | (159,693) | 348,471 | 1,417,580 |
| *និយ័តភាពលើ៖* | | | | |
| ចំណូលការប្រាក់ | (3,936,438) | (125,127) | (4,061,565) | (16,522,446) |
| ចំណាយការប្រាក់ | 648,747 | 88,539 | 737,286 | 2,999,279 |
| ការខាតបង់ឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុសុទ្ធ | 41,213 | 86,618 | 127,831 | 520,017 |
| រំលស់ | 149,576 | (69,078) | 80,498 | 327,466 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 138,183 | - | 138,183 | 562,128 |
| កាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | (3,350) | 73,651 | 70,301 | 285,984 |
| (ចំណេញ)/ខាតពីការប្តូររូបិយប័ណ្ណបរទេសមិនបានទទួលស្គាល់ | (41,188) | 43,635 | 2,447 | 9,954 |

របាយការណ៍លំហូរទឹកប្រាក់ និងសេចក្តីសង្ខេបនៃធាតុ ដែលរងផលប៉ះពាល់ដោយការរាយការណ៍ឡើងវិញនៃព័ត៌មានប្រៀបធៀប និងការកែតម្រូវកំហុសដូចដែលសង្ខេបខាងលើមានដូចខាងក្រោម៖ (ត)

**របាយការណ៍លំហូរទឹកប្រាក់ (ត)**

| | 2021 | | | |
|---|---|---|---|---|
| | ដូចដែលបាន រាយការណ៍ពីមុន | និយ័តកម្ម | ដូចដែល រាយការណ៍ឡើងវិញ | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ (ត)** | | | | |
| *បម្រែបម្រួលនូវ៖* | | | | |
| ឥណទានផ្តល់ដល់អតិថិជន | 2,820,775 | (13,054) | 2,807,721 | 11,421,809 |
| ទ្រព្យសកម្មផ្សេងៗ | (16,656) | 15,964 | (692) | (2,815) |
| បំណុលផ្សេងៗ | (119,501) | 132,196 | 12,695 | 51,644 |
| សាច់ប្រាក់ទទួលបានពីប្រតិបត្តិការ | 189,525 | 73,651 | 263,176 | 1,070,600 |
| ការប្រាក់បានទទួល | 3,973,624 | - | 3,973,624 | 16,164,702 |
| ការប្រាក់បានបង់ | (651,194) | - | (651,194) | (2,649,057) |
| ពន្ធលើប្រាក់ចំណេញបានបង់ | (187,052) | - | (187,052) | (760,928) |
| កាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | - | (73,651) | (73,651) | (299,612) |
| សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ | 3,324,903 | - | 3,324,903 | 13,525,705 |

របាយការណ៍លំហូរទឹកប្រាក់ និងសេចក្តីសង្ខេបនៃធាតុ ដែលរងផលប៉ះពាល់ដោយការរាយការណ៍ឡើងវិញនៃព័ត៌មានប្រៀបធៀប និងការកែតម្រូវកំហុសដូចដែលសង្ខេបខាងលើមានដូចខាងក្រោម៖ (ត)

**របាយការណ៍លំហូរទឹកប្រាក់ (ត)**

| | 2021 | | | |
|---|---|---|---|---|
| | ដូចដែលបាន រាយការណ៍ពីមុន ដុល្លារអាមេរិក | និយ័តកម្ម ដុល្លារអាមេរិក | ដូចដែល រាយការណ៍ឡើងវិញ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (24,277) | - | (24,277) | (98,759) |
| ការដកប្រាក់បញ្ញើតាមកាលកំណត់ | 1,100,000 | - | 1,100,000 | 4,474,800 |
| សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពវិនិយោគ | 1,075,723 | - | 1,075,723 | 4,376,041 |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| ការទូទាត់សងប្រាក់កម្ចី | 1,667,800 | - | 1,667,800 | 6,784,610 |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | (5,094,249) | - | (5,094,249) | (20,723,405) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន | (3,426,449) | - | (3,426,449) | (13,938,795) |
| **ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | 974,177 | - | 974,177 | 3,962,951 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី1 ខែមករា** | 760,202 | - | 760,202 | 3,075,017 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | 27,891 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី31 ខែធ្នូ** | 1,734,379 | - | 1,734,379 | 7,065,859 |

# ការិយាល័យកណ្តាល និង សាខា

## ១/ ការិយាល័យកណ្តាល

អគារលេខ ៥០២ហ្សេ-៥០២ហាស មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ (ទល់មុខវ៉ាដាតេជោសែន)

ទូរស័ព្ទ : (៨៥៥) ២៣ ៩៩ ៣៣ ៣៣ / ០៩៣ ៤៩ ៦៦៦៦
អ៊ីម៉ែល : info@samrithisak.com
គេហទំព័រ : www.samrithisakmicrofinance.com.kh

## ២/ សាខាខណ្ឌពោធិ៍សែនជ័យ - សង្កាត់កាកាប

ផ្ទះលេខ ៦០០D ផ្លូវ ១១០ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : (៨៥៥) ០៩៣ ២២២ ៦៦៩ / ០៩៣ ២២២ ៨៧៤
អ៊ីម៉ែល : bm_psc@samrithisak.com
គេហទំព័រ : www.samrithisakmicrofinance.com.kh

## ៣/ សាខាចំការមន

អគារលេខ ៥០២ហ្សេ-៥០២ហាស មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ : (៨៥៥) ៩៣ ៨០៨ ១៨២ / ០៩៣ ២២២ ៨៦៣
អ៊ីម៉ែល : bm_ckm@samrithisak.com
គេហទំព័រ : www.samrithisakmicrofinance.com.kh

## ៤/ សាខាស្រុកស្អាង

ផ្ទះលេខ ១៩១ ផ្លូវ ២១ ភូមិព្រៃករុន ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល

ទូរស័ព្ទ : ០៩៣ ២២២ ៨៩៤ / ០៩៣ ២២២ ៦២០
អ៊ីម៉ែល : bm_sng@samrithisak.com
គេហទំព័រ : www.samrithisakmicrofinance.com.kh

## ៥/ សាខាខេត្តបាត់ដំបង

ផ្ទះលេខ ១០៣ ផ្លូវជាតិលេខ៥ ភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

ទូរស័ព្ទ : ០៥៣ ៩០០ ៩១០ / ០៩៣ ២២២ ៩៨០
អ៊ីម៉ែល : bm_btb@samrithisak.com
គេហទំព័រ : www.samrithisakmicrofinance.com.kh

## ៦/ សាខាខេត្តតាកែវ

ផ្ទះលេខ១២-១៣ ផ្លូវជាតិលេខ២ ភូមិឡើង សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ

ទូរស័ព្ទ : ០៣២ ៩០១ ៩០០ / ០៩៣ ២២២ ៥៣៥
អ៊ីម៉ែល : bm_tko@samrithisak.com
គេហទំព័រ : www.samrithisakmicrofinance.com.kh

## ៧/ សាខាខេត្តកំពង់ស្ពឺ

ផ្ទះលេខ ១២-១៣ ផ្លូវជាតិលេខ៤ ភូមិមុខខេត្ត  សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

ទូរស័ព្ទ : ០៩៣ ៤៤៤ ៩៣១ / ០២៥ ៩៨៧ ២២០

អ៊ីម៉ែល : bm_kps@samrithisak.com

គេហទំព័រ : www.samrithisakmicrofinance.com.kh



www.samrithisakmicrofinance.com.kh